# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា ចំងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដកៈនៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

| | | |
|---|---|---|
| លោក ហេង-យ៉ាន់ | កំពូលស្នេហា (តមក) . . . . . . . . . . . | ៨០៥ |
| លោក ធុយ-ប៊ុនសួរ | ឯកសហស្សរាត្រី ភាគទី ១២ (តមក) . . . . | ៨៣០ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ព្រះរាជប្រវត្តិ ព្រះបាទសម្ដេចព្រះជ័យជេស្ឋា (ព្រះអង្គសួរ) (តមក) . . . . . . . . . | ៨៣៧ |

*ផ្នែកសាសនា*

| | | |
|---|---|---|
| ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ | ប្រយោជន៍របស់ធម៌ក្នុងពុទ្ធសាសនា (តមក នឹងចប់) . . . . . . . . . . . . . . | ៨៤៧ |
| ពុទ្ធសាសនបណ្ឌិត្យ | ប្រវត្តិព្រះធម្មចរិយាព្រំទ្ធវិចិត្រសេដ្ឋាភជាគណៈ (កែវ-ដួន) ចៅអធិការវត្តភ្នំសំពៅ មេគណខេត្របាត់ដំបង . . . . . . . . . . . . | ៨៥៦ |

ឆ្នាំទី ១៨ — លេខ ១០ ខែឧក្តូប្រ៊ ១៩៤៦ — ថ្លៃជាវៈ ១ ឆ្នាំ ៣៥ រៀល ។
N° 10 1946

# កំពូលស្នេហា

## លោក ហេង-យ៉ាន់ រៀបរៀង (តមក)

---

"អ្នកឯងនេះជាមនុស្សក្រួត ពីព្រោះទុកជាអ្នកកើតទុក្ខ កុំថាត្រឹមមួយឆ្នាំពីរឆ្នាំ រហូតដល់អស់មួយជីវិតអ្នកឯងផង ក៏អ្នកឯងមិនងាយនឹងបានព្រះបុត្រីធ្វើកង់រទេះអ្នកដែរ ល្ហើយវិលទៅលំនៅវិញទៅជាជាងទៅរកកាប់តាំងឈើក្នុងព្រៃធ្វើកង់រទេះទៅ" ។

ចំណែកលោកក្ដមានឋានៈជាបុរសប្រែសទ័យ នឹងឈានរកទេព-ធីតាក្រុងក្ដីពេញឯណាក៏បាន នេះឃើញថាគាត់មិនដល់ ប្រាកដមិនជាប់តែម្ដងហើយ បើនាងស្ត្រីជាមួយផងនោះនាំបើសង្ស័យខ្លះ នេះបើនាំព្រះអើយកន្ទើយធ្វើងផ្ទៃកាយបុគ្គលយ៉ាងនេះ មុខជាអស់ផេតការគាត់ប្រយោជន៍ផតអំពើ ឧត្តមកើយកម្ម! ជីវិតលោកក្ដសោះសូន្យស្រងូតស្រងាត់ បីដូចមនុស្សមានទោសដែលគេនិរទេសឲ្យទៅនៅកណ្ដាលកោះតែម្នាក់ឯង ,ចុះលោកក្ដលើសគ្រប់ទំអ៊ីបានជារងកម្មដូច្នេះ ធ្វើឲ្យគេថ្កុំឋានៈអាជ្ញាឯណាមួយឬ? ។ លោកក្ដពញ្ញូងសព្វគ្រប់ទៅក៏ឃើញថាមានហេតុមែន គឺព្រោះខ្លួនជុនជាប់ផតទំពីង បានជាគេហ៊ានមើលងាយដល់ថ្នាក់នោះ ធ្វើឲ្យដូចជាទឹងខោងបង្អើលតាបដូច្នោះ ប៉ុន្តែសេចក្តីស្នេហារបស់លោកក្ដ មិនមានទាក់ទងដល់ទ្រព្យសម្បត្តិ, ដល់យស

ស្តី ផល់ប្រយោជន៍ឯណាទីមួយឡើយ ជាសេចក្តីស្នេហាដ៏ភ្ជាប់ខ្លួន បំផុតក្នុងលោក ។

អនិច្ចាអើយ ! សេចក្តីខ្សត់ទ្រព្យ សេចក្តីក្រនាំឲ្យឃើញថាជាបំណាំង ពិតសមស្តី សេចក្តីខ្សត់ទ្រព្យសម្បត្តិជាមូលនៃសេចក្តីវិបត្តិគ្រប់ពពួក នៃជីវិត ។ កាលបើសោភ័ក្ត្រគិតដូច្នោះហើយ ក៏ត្រូវក្លាយជាទុក្ខបួល កាន់ជំរះណាក ។

ព្រឹកឡើងជាថ្ងៃអាទិត្យ សោភ័ក្ត្របែកគំនិតថ្មីរៀបខ្លួនទៅលេង កោះក្របីទៅកណ្តាលបឹងមុខនាវាលោហសៀលដែលទៅបស្ចិមទិស ។

ស្រីព្រះអាទិត្យស្រទន់ ៗ ទៅហើយ មានខ្យល់រំភើយរំហើយ ស្រួល ផ្ទុះទ្រួដ្រញញយោយកន្លាញវិត សោភ័ក្ត្រចុះទូកទៅលេងកោះ លុះដល់ហើយក៏លោតចុះទៅអង្គុយលេងលើខ្សាច់ បែរមុខមើលទឹកហ្លួ ល្ហាចទៅឆ្ងាយ ស្តាប់សំឡេងត្រញត្រុំគ្រេង ៗ ឯអាកាស សត្វខ្លែងហើរខ្ពស់កយកន់ម៉ោរាំណើ ត្រដាងស្លាបពណ៌សង្កៀវភ្លំ- ភ្លឺតតាក់ ។

អណ្តូងយ៉ាងទៅបកកំប៉ុងជាអណ្តែតអណ្តូងចិត្តឃ្លង់ឃ្លោងមិនទង់ទង់ គួរ ឲ្យនឹកស្រងៃ តែឯការស្រមៃរបស់យុវជនខានគ្នានេះក្រៅអំពីនឹកដល់គូ ជីវិតរបស់ខ្លួន ចុះនៅពេលនោះទីនឹងឲ្យសោភ័ក្ត្រនឹកដល់នារីណា បើនែ ស្រឡាញ់នាងស៊ូវិច្ឆាហើយនាងមិនស្គាល់ផង !

ទុកជាសោភ័ក្រ្តមានទុក្ខធ្ងន់យ៉ាងណាក្តី ធម្មជាតិអាចផ្សាយនូវអានុ-ភាពដ៏ឧត្តមលើបុរសនោះបាន នាំឲ្យរំភើបអារម្មណ៍ចុះ ក្រចៀកព្រមទទួលស្តាប់នូវបទចំរៀងនៃលោក ដែលសត្វមកពីគេច្រៀងខ្សឹបលាន់ទៀតៗ ហាក់ត្រជាក់ចិត្ត វិញ្ញាណអណ្តែតត្រសែតដល់នគរមណ្ឌលណា ខ្យល់ត្រជាក់មកអប់រមគ្គសព្វាង្គកាយ សោភ័ក្រ្តនឹកស្មានថាខ្លួនមិនមែនស្ថិតលើផែនដីដូចធម្មតា ហាក់ដូចជាល្ហល្ហែរគ្មានព្រំប្រទល់ដូចជាអ្នកទន់ល្មើយវិស័យសំឡឹងពីក្រោម ក្នុងពេលនោះសោភ័ក្រ្តលែងនឹកនាដល់អ្វីទៀត ទុក្ខសោកទាំងប៉ុន្មានខ្ចាត់ខ្ចាយបាត់ចេញពីសន្តានបានមួយគ្រា ។

ក្រោយនោះបន្តិច ជើងមេឃងងឹតស្រទំៗ ពពកស្វាតមកបន្តគ្នាបាំងស្រះជាសំពត់ពណ៌ក្រមៅ ក្រឡាពាសពេញអាកាសបាំងមេឃជុំជិត មានខ្យល់ខ្លាំងផាត់លំអងទឹកសាចមកលើខ្លួនសោភ័ក្រ្ត ធ្វើឲ្យអ្នកភ្ញាក់ព្រឺតចេញពាក់កណ្តាលមួយរំពេច ងើបមើលលើឃើញសុទ្ធៗជាសញ្ញាថាមុខជាទឹងមានព្យុះភ្លៀងធ្លាក់មិនយូរប៉ុន្មាន សោភ័ក្រ្តនឹកអរព្រួចទើបពោលឡើងថា :

" ឱព្រះពាយទេវបុត្រ យ៉ាងរំពេចហាក់ខានមកកុំឲ្យវង្វេង ដើម្បីទឹងញ៉ាំងផ្គរឲ្យកម្រើកញាប់ញ័រ ហើយរោលខ្លួនលោកជាំៗ ស្រោចលើកោះនេះឲ្យលិចបាត់ទៅ ឬមួយចាំងខ្លួនខ្ញុំទៅជាមួយផង ឲ្យរមៀល

លើគ្រែសកណ្ដាលបាតទន្លេនេះ ព្រោះខ្លួនខ្ញុំជាមនុស្សអភ័ព្វតែម្ដងហើយ ប្រាប់គ្នា ទឹកឲ្យខ្ញុំរស់នៅលើផែនដីទៅទៀតដូចម្ដេចបាន ខ្ញុំលែងចង់រស់នៅទៀត ព្រះវៀតបិតុណាសំលាកអើយ !

រួចហោក្រែប្បេបក្រែកដាសុខ បុរសយកខ្សាច់ជាធ្លាប់របស់ខ្លួននៅថ្ងៃគោរពងារ ។

ខណៈនោះ ព្រះព្យាកាបង្កើតមានឡើងនូវត្រឹកតក្រែង ស្ងួតស្ងៀមស្ងាត់ព្រៃពេល បក្សាបក្សីម្ចាស់កក្រែទំនើបរបស់បក្ខីតកស្ទូតកិតក័យរលាបទក់ព្រោកពឹកៈជិតវែកពាត់ៈត្រា ខ្លោលបុះខ្លោលស្ទើរខ្ទប់ខ្ចាត់កឋំណើ ប៊ិនក្រាំទំរាវឲ្យខ្ទួចខ្ទី ស្រាប់តែមួយសន្ទុះផ្ដួលជ្រលទៅទិសម្ខាងព្រាងសន្ទឹតគឹកកក៏ទំនើជួបសំរែត ជំហោ ! ប្រហែលជាបានអ្វីធ្លាញពីរហា ហើយមើលទៅ ។

ស្រាប់តែព្រសួរនាត់មនុស្សស្រែកច្រឡូនឡើងយ៉ាងខ្ទួតសង្ស័យសោកក្រៃក្រែទេត្រមើលទៅឃើញទូកតូចមួយកំពុងផ្អៀងផ្អងតមលំលិចបូកលទៅមុខ ចូលថយមកក្រោយវិញវិលវល់នៅតែមួយកន្លែង អ្នកកាយសារទាំងប៉ុន្មានប្រញាប់ប្រញាល់លោតចុះទឹក នាំគ្នាហែលរកនាក សំណាងមានទឹកត្រង់នោះរាក់ត្រឹមជង្គង់ បាននាំគ្នាវិលុយកាត់ទកលាយសេចក្ដីពិបាក ណាក់ឡាំងខ្យល់ កកាក់ឡាំងរលកជន់ អ្នកមានក័យអស់នោះមានគ្នាចំនួន ៦ នាក់ អ្នកនៅតែរទាក់ថ្កូលមកដល់ខ្សាច់មុខ

ទីនិមនុស្សកណ្តាលអាយុម្នាក់ ព្រមទាំងភរិយានិងកូនប្រុសកូនស្រីពីរនាក់ឈរនៅលើឯបណ្តើរកាន់ដៃគ្នាបណ្តើរទៅមុខទៅក្រោយ ចែងាប់ព្រឹលគ្នងទឹក កុមារីនោះទទឹកសក់អ៊ុតត្រីត្រួតអស់ពោះកាសប្រែឡាក់ប្រឡូសតាក្រក់មើលក្រពេក ដោយសេចក្តីព្យាយាមខំតស៊ូដល់កំឡាំងធាតុនៃលោក ទើបបានមកដល់កោះ ដល់ហើយក៏អស់កំឡាំងស្តូកដេកលើខ្សាច់តែម្តង ។

សោភ័ក្ត្រពិនិត្យមើលមុខគូគទាំងនោះ ស្គាល់ជាក់ថាវៀញ្ញាកិរបស់ណាជនេត្រនារី តែនាងមិនឃើញ ក្លូតសោភ័ក្ត្រត្រឡប់ទៅរកគូកដែលលិចបាត់ទៅហើយ កន្ទុកនោះ មានអ្វីសៗ កកើតបង្គិចៗ ដូចជាពន្លឺមនុស្ស សោភ័ក្ត្រខំប្រឹងបំពើតមើល ។ ស្រាប់តែអ្នកម្តាយរបស់នាងផ្តើលប្ចាក់ក្បែរស្រែ ងើបឡើងដង្ហោយហៅ សំឡេងយំនិងយាំងស៊ូយក្ដើយកថបកវិញ មាតារបស់នាងលូកដង្គន់ថ្ពុះយកដៃតក់ទ្រូងទេ ហើយបន់ស្រន់ទេវតាកេព្វតា ទេវឲ្យជួយស្រោចស្រង់ពន្លកហ្វូចេយផងតែខ្យល់កាន់តែបក់ខ្លាំង ។ រលកកាន់តែខ្លាលស្ទួនកំឡើង មាតាផុតសង្ឃឹមដួលសន្លប់លើខ្សាច់ ។

ចំណែកសោភ័ក្ត្រកើបកន្ទុំដួងចិត្តពន់ប្រមាណ បារម្ភដល់ហៀរទឹកភ្នែក ប្រាកមកហើយមកគិតថា បើអាត្មាអញមិនបានរួមជាមួយនឹងណាជ-នេត្រនារីវេលាដែលរស់នៅ ក៏ហ៊ាប់ទៅនាពេលនេះគង់នឹងបានគ្នាឯបាត.

ខ្លួនមិនលែងទេ  ទុំនេះហេតុតែសំណាងមិនបានជាមកប្រទះគ្នា ។ សោភ័ក្រ្តចិត្តគេព្រួយបំរុងខ្លួនទឹងស្លាប់ជាមួយទឹងនាង  តែចកឃើញសេចក្តីទុក្ខរបស់មាតាដែលស្រឡាញ់បុត្រ  សោភ័ក្រ្តក៏ស្រយុតចិត្តទឹកកាណាតជល់ដើមព្រៃមនុស្សជន្លា  ទើបលែងទឹកនាងលំអុំទៀត ក្រោកស្ទុះចុះទឹកហែលផ្រមដំទៅរកទូកតែម្តង  ដោយហេតុជាអ្នកចុះខាងផ្លូវហែល  ទើបសោភ័ក្រ្តមិនបានតក់ស្លុតដល់ប៉ុន្មានសែសក់ហែលកាត់សេចក្តីតក់មនៃបណ្តុកផលយ៉ាងអង់អាចទៅជួយគូជីវិត ។

ដោយសេចក្តីព្យាយាមយ៉ាងមានឧស្សាហ៍  សោភ័ក្រ្តបានដល់ទូកឃើញណាគ្រុជនេត្រប៉ាត់ស្មារតីលែងកើតដៃជើង  តែមុខនាងនៅតែស្រស់ញញឹម  ហាក់ដូចជាមិនព្រមចុះចាញ់ដល់ហេតុវិបត្តិនៃផ្ទៃលោក សោភ័ក្រ្តឃើញហើយស្រយាកចិត្ត  ទឹកស្មារជាអង្គទេពធីតាក្សាទំខ្ញុំដែលបេះជើងកើយលើផ្ទៃទឹកជាវិមាន  ទើបលូកដៃទៅទីងទប់ក្រសោបបីស្រាប់តែមានរលកធំមួយកំឡែងមកបោកខ្លួនសោភ័ក្រ្តទៅក្រោយឃ្លាតពីទូកបំនូនមួយព្យាម  សោភ័ក្រ្តក៏ខំប្រមូលអស់កំឡាំងទប់ខ្លួនដើម្បីខិតស្ទុះទៅជណ្តើយនាងចេញពាក្ដណ្តាប់ដៃនៃមច្ចុរាជ  ស្រាប់តែឃើញទូកលិចបាត់ទៅក្នុងទឹកទៅ  សោភ័ក្រ្តខំជើងដួលលុតផ្ទន់លើកដៃទាំងពីរឡើងទៅលើបន្ទូលឡើងសេចក្តីសោករដោយពាក្យដូច្នេះ :

“ខ្ញុំអស់លោកទេវតាដែលថែរក្សាទន្លេនេះ ខ្ញុំសូមសំដែងសេចក្តីត្រេកអរ[illegible]ន់ស្រប់ចំពោះលោក ព្រោះខ្ញុំបានសម្រេចដូចចំណង់ហើយ គឺបានជួបនឹងណាដុនេត្រដែលខ្ញុំស្រឡាញ់ស្មើជីវិតខ្ញុំទៀត” ។

លោកគ្រូបិទភ្នែក ស្រាប់ដូចជាមានអ្វីត្រជាក់ៗ មកប៉ះនឹងខ្លួន បើកភ្នែកឡើង ឱ! គួរឱ្យភ្ញាក់ខ្លួន គួរឱ្យសប្បាយ! គួរឱ្យសុខកាយសុខចិត្ត ខ្លួនណាដុនេត្របានមកដល់ខ្លួនលោកគ្រូ! ព្រោះមានរលកបោកខ្លួននាងមកពិតប្រាកដ ជាដោយកុសលនាអ្នកទាំងពីរ មិនត្រូវស្លាប់ក្នុងបាតទន្លេ ហើយត្រូវជួបគ្នានៅនាដែនមនុស្សលោក?

បាននាងនៅទីនេះហើយ · លោកគ្រូក៏ឱបនាងជាប់លើដើមទ្រូង ដោយសេចក្តីផុតសង្ឃឹម សំឡឹងមើលមុខនាងរំភើបល្អឡើង ទើបមិនចង់នាំនាងយកទៅឱ្យជួបនឹងមាតា ដែលកំពុងសង្រេងសង្រែនោះឡើយ គិតតែគិតនឹងនាំនាងទៅឱ្យឆ្ងាយ ឆ្ងាយពីគេ ពងស្រមើស្រមៃតែពីរនាក់ ដើរតាមក្តាមខ្លួនចិត្តប្រាថ្នាជីវិតតែមករកគិតឃើញថា :

“អាត្មាអញចង់បានព្រះបន្ទូល ដែលដុតចិត្តស្រយនឹងឈានបាត ប្រាថ្នា ឥឡូវបែរជាមកនៅក្នុងក្តាប់ដៃទៅវិញ · ក៏ឃើញថាលោកភ្លេចនាខ្ញាំង ប៉ុន្តែអាត្មាមិនសមស័ក្តិនឹងពន្ធព្រះបន្ទូលនោះ ណាមួយ ចុះគួរសឹងព្រះបន្ទូលដល់តាកការវិញ ធ្វើម្តេចឯងការជោគជាប់ខ្សែទ្រព្យសម្បត្តិ” ។

ក្នុងវេលានោះ ស្រាប់តែមានភ្លៀងធ្លាក់ខ្លាំងៗមក សព្វលោកធ្លាក់ស្ងាត់ស្ងៀមក្នុងទន្ទេវិស័យដូចមហាស្រពសមរស្ម គឺជាប្រគំឡើងដើម្បីជំនួសផ្គុំណាំដន្ត្រីទិងសោកក្រ្ត ដែលបានឧប្បត្តិរឿងនេះឡើងដោយយមនោគតិរបស់ខ្លួន ព្រោះនឹកថា បើមនុស្សលោកមិនយល់ព្រមឲ្យខ្លួនដំណើរណាំដន្ត្រីជាមិត្រមេត្រីនឹងគ្នា ក៏គង់តែទេវតាជួយជ្រោមជួយញែដែរ តែប៉ុណ្ណឹងសោកក្រ្តក៏សុខចិត្ត ទើបបំណុំដន្ត្រីយកទៅប្រគល់ឲ្យម្ចាស់របស់គាត់វិញ ។

ចុះឯសោកក្រ្តគាត់ចិត្តថែបណា នៅវេលាដែលនាងឃ្លាតចេញពីដៃទៅហើយ ហាក់ដូចជារបះដួងរបស់សោកក្រ្តឃ្លាតចេញពីដើមទ្រូងស្ទើរផ្លោះឯង ។

ពេលនោះខ្យល់ស្ងប់ស្ងាត់ចុះ ភ្លៀងដាច់គ្រាប់ហើយ ផ្ទៃមេឃក៏ដូចដើមវិញ មេឃស្រឡះជួរផងនឹង ព្រះអាទិត្យហៀបនឹងអស្តង្គតទៅ ញញឹមព្រាយមករកផែនដី បក្សបក្សាចេញពាក់ទ្រនំហើរពាសពេញ សំឡេងសើលទៅព្រាំងទន្ទេឯណោះ ប្រាសាទបរិញ្ញពាន់ទូរុគគ្នាន់ព្រាងព្រាតទៅលើមេឃ គឺផ្ចិតគួរឲ្យស្ញើចដល់ចិត្ត ឃើញកំពូលខ្ពស់ត្រដែតហាក់នឹងកណ្តោតត្រែសេគទៅ ដោយហេតុដែលមានទឹកទ្រពះព្រាមនឹងអាកាសជៀរស្រអាប់តីលើ ទ្រង់ដូចស្រឡះត្រចះត្រចង់កំពុងពេញទំហឹងមានពន្លឺស្មើ ដែលយើងគួរទុកដូចជារសជាតិនៃក្រុងនគរសម័យថ្មីនេះ ។

មាតាបិតារបស់ណាងខេត្រកំពុងរៀបចំធ្វើបបមំពក្យាបាលផល់បុត្រ សំឡាញ់ សោកក្រោចាលភ្នែកសំឡេងណាងខេត្រ ដែលគេយកលើក្តៅម្ដាយ ដៃច្រេងញាក់ទៅលើខ្លួច ដៃស្ដាំគងលើដើមទ្រូង សក់នាងរំ-សាយតាមខ្យល់រវិចៗ មុខនាងគឺតែមានសំរស់ឡើងត្រជាក់ទៅដោយដំណក់ទឹក ដែលត្រូវពន្លឺថ្ងៃមកដេញផ្លេកៗដូចត្បូងពេជ្រ សោកក្រោខំសំឡឹងមើលនាងមិនដាក់ភ្នែក សំឡឹងមើលឲ្យអស់ចិត្តដើម្បីនឹងថតនូវរូបរបស់នាងឲ្យជាប់នឹងដួងភ្នែក ឲ្យធ្លាក់ជាប់ខ្លួនជាទិច្ចទីវន្ទកងហឫទ័យរបស់សោកក្រោ ព្រោះឃើញនាងគ្រាគេះលែងឃើញទៀត លុះសំឡឹងអស់ចិត្តហើយក៏ប្រែងប្រៀបរៀបខ្លួនទទឹងវិលមកលំនៅវិញ ចួនជាចានទូកដដល់ទីនោះក៏ឡើងជិះតែម្ដង ។

កាលបើផុតពីនោះមក សោកក្រោនៅតែយកនឹកមើលនាងទៅឡើយ សំឡឹងដោយកាការធ្វុកបន្ទុំ ចិត្តមិនចង់ទៅណា បង់តែនៅអង្គុយគយគន់លំអរបស់នាង តែដោយខ្ញាចនាងភ្ញាក់ខ្លួនឡើង ក៏ដាមើលឆ្ងាយដោយកាការជ្រួលៗ ។ ឱស្រីស្រណោះអាឡោះអាល័យរូបឆោមកែវពន្លក! ស្រណោះសំឡេងពីរោះដែលពន្លូវសេចក្ដីត្រជាក់ស្រោចលើចិត្ត ដែលកំពុងឆេះពេលកាលឲ្យរលត់ទៅវិញបាន! ស្រណោះប្ដូកផ្សៀងផ្អឹតនិយាយមកកេ! ស្រណោះភ្នែកខ្មៅមានពន្លឺ ស្រណោះត្រចៀកស្រណោះសព្ទ! ស្ដាយអើយសែនស្ដាយមិនបង់ឃ្លាតឆ្ងាយសោះ

តែខ្លួនជាមនុស្សក្រោកតាបមោជិតអ្នកមានពុំបាន  គ្មានតែបែកចេញ
បែកមកដោយពុតតែរាំងដើមផ្ទឹងស្ទើរខឹងប្រែក្លាយជាពីរបីកាន! ទណ្ឌ
ទេត្រឹមតែមានសមស់ហើយ ។

វគ្គទី ១២

## គូស្រឡាញ់មួយគូ

នាពេលសោយណ្ហសម័យថ្ងៃសៅរ៍ មនុស្សម្នាគឹកកាប់ពាសពេញ តែផ្សារ អ្នកហើយ ខ្លះដើរលេងកំសាន្តហើយខ្លួន ខ្លះជិះទៅមើលភាពយន្ត ខ្លះគង់ថ្លៃទិញអីវ៉ាន់ ពួកអ្នកលក់ផ្លែឈើប៉ុន្មានញាប់ដៃ ប្តូរមួយដេញថ្លៃជាមួយអ្នកទិញ លាន់ញាញមិនដាច់សំឡេង ។ មានយុវជនឈរមុខអ្នកដើរអ្នកទំនិញរបស់ខ្លួនឱ្យគេចូលចិត្តទិញ ចំណែកពួកចិនស្ងៀតទៅត្រឹមនៅមុងយនៅក្រោយប្រអប់កញ្ចក់ជាច្រើន មានរោគការព្យួរយ៉ាងដុំទិញខ្លួន ធ្វើព្រងើយដូចជាអ្នកតាមិនអើពើនឹងអ្នកទិញប៉ុន្មាន ។ ចំណែកពួកខ្មែរជាតិវិញមានចំនួនជាច្រើន សុទ្ធតែអ្នកដើរកំសាន្តទិញរបស់របរ ចំណែកខ្មែរអ្នកលក់នោះមានត្រឹមតែពីរបីនាក់ប៉ុណ្ណោះ ដែលចត់ជើងស្ពាយហួមកណ្ដាលក្រោមឈុនទីរបាត្រុង ។ ចុះហេតុដូចម្ដេចបានជាមានអ្នកលក់ដូរជាតិយើងស្ដួចស្ដើងយ៉ាងនេះ? ប្រហែលជាខ្មែរសម័យឥឡូវជាប់ចិត្តផុតពេកព្រោះបុរសគេ ដែលជាអ្នកខាងនិស្ស័យខាងផ្សាជំនួញ ប៉ុន្តែដែលជាអ្នកកសាងធំចំបងនឹងជាអ្នកស្រឡាំងគាំងក្នុងក្រុងជីង?

បណ្តាព្រៃជុំជនកុះករ សោភ័ក្ត្រគាប់ចុះទៀងទាល់តែឯងមើល នាយមើលអាយបំភ្លេចខ្លួន ព្រោះទឹកបារម្ភដល់ណាផុតេត្រជាក់ខ្លាំង . មិនដឹងជានាងធ្លាក់សះស្បើយហើយឬនៅ នឹងទៅសាកសួរដល់អ្នកណាអេះ នឹងទៅលេងផ្ទះអាចារ្យដូចរាល់ខួប ។ ភិតុងតែខ្វក់ខ្វល់កង់ចិត្ត ស្រាប់តែឮស្គរគេហៅស្ទៀងៗ នឹងត្រៀក បែរមើលទៅប្រទះនឹងឪពុកម្តាយណាផុតេត្រនៅពីមុខ ឪពុកនាងពាក់អាវគាក្លកម្លោះក្រឡង់មាត់អាល ដំណើរហើសហៅគួរជួបកូនគេង ម្តាយនាងមានសាច់ជន្ទបមុខញញឹម ព្រាយតែគួតមុខគាប់តែចិត្តល្អ ដំណើរស្រគត់ក្នុងសា សោភ័ក្ត្រក៏លើកដៃសំពះសួរ ម្តាយនាងក៏លើកដៃហើយសួរថា :

"ថ្ងៃនេះ ក្មួយមិនធ្វើការទេឬអី?

"បាទទេ ពល់តែល្ងាចថ្ងៃសៅរ៍ខ្ញុំបានឈប់សម្រាកខ្លួន អត់ទោសអ្នកមីងក្មួយអ្នកមីងបានត្រាន់បើហើយឬនៅ?

"បាទហើយក្មួយ មីងមិនដឹងបានអ្វីតបស្នងសងគុណឯងទេក្មួយមានគុណនឹងក្មួយមីងច្រើនណាស់ បានសង្គ្រោះជីវិតជួយកំឡុងរបពិភ័យ ហើយកំចង់ចូលនឹងក្មួយឯង បើដូច្នោះមានតែក្មួយទៅជាមួយនឹងមីង មីងតែងតែគេងឯកាលថ្ងៃ ឥឡូវបានជួបហើយ មីងមិនឱ្យទៅណាទេ" ។

សោភ័ក្ត្រនឹកអស់អែកប្រែកក្តីព្រមទៅ ដល់ត្រូវចង្កូណាស់ ក៏ពាល់មើលគ ដើរក្បែរៗតាមម្តាយណាផុតេត្រ ពេលនោះសោភ័ក្ត្រ

អរផងភ័យផង អារម្មណ៍ក្តុកបានឃើញលំអរបស់នាង ត្រចៀកបានស្តាប់ពាក្យពីរោះរបស់នាង មាត់បាននិយាយសាកសួរនាង ដែលភ័យនោះគឺភ័យដោយបានជួបមុខនាង ក្រោយហេតុភេទដែលហួសកន្លងទៅថ្មីៗ មិនដឹងជានឹងលើកមុខថែបណា ទើបចរចារកនាងដោយពាក្យដូចម្តេច?

លុះដល់ធរណីផ្ទះនាងហើយ សោភ័ក្ត្រក៏កើបវែងរកងចិត្តគត់ៗ បមា ញ័រជើងញ័រដៃញ័រដើមទ្រូងតិចៗ ។

“កញ្ញនេត្រនារីអើយ មាតានាងនៅស្រុកហៅ ។

“ចាស” សំឡេងស្រួយស្រស់ចេញពីក្នុងមក មិនយូរប៉ុន្មាន នាងក៏នាំគងចេញមកក្រៅ ញញឹមញញែមទទួលមាតា ដល់ក្រឡេកឃើញសោភ័ក្ត្រគំគាំងដំណើរ មុខឡើងក្រហមឆាំងរស័យដូចត្រូវកំដៅថ្ងៃ បបូរមាត់គាំងទំនងដូចញញឹម តែភ្នែកវិញមើលកញ្ចប់ដែលម្តាយនាងយួរនៅដៃទៅវិញ ។

សោភ័ក្ត្រឃើញមុខនាងហើយស្ងាត់ចិត្ត ស្រពោនមុខមួយរំពេច ដូចទទឹងទើបពីត្រូវ គិតថាតុខទៀតហើយម្ចាស់ថ្លៃអើយ! ទើបរេកគេចចេញមកក្រៅ ដាច់ចិត្តទឹងទិលត្រឡប់ទៅវិញ ស្រាប់តែកញ្ញនេត្រដើរមុខឡើងញញឹមយ៉ាងក្រៀម ។

“អញ្ជើញចូលមកក្នុងបង” ។

សោភ័ក្រ្តស្ទុះសំដៅទៅខាងវិញដោយសំឡេងញ័រ រូបកាយដើរល្វល ទៅយ៉ាងញញើតញញើម អង្គុយលើកៅអីមួយនៅជិតនោះ ក្រពុះទាំងប៉ុន្មានចូលទៅក្នុងអស់ នៅសល់តែកំលោះចិនក្រមុំពីរនាក់នោះ ។

នៅស្ងៀមចំនួន ៥ នាទី កំលោះនោះចាប់ផ្តើមសេចក្តីសន្ទនាឡើង តែញ័រមាត់ពាក់កណ្តាលចំពាងទៅវិញ ។ ខណៈនោះណារុងនេត្រសំឡឹងមើលចំនឹងក្លែកសោភ័ក្រ្តយ៉ាងយូរ ហើយបង្ហូរទឹកមេត្រីចិត្តមកលើសោភ័ក្រ្ត រួចនាងនិយាយឡើងដោយសំដីទន់ភ្លន់ត្រជាក់ចិត្តថា ៖

"បងស្អប់ខ្ញុំណាស់ទៅឬអី ចាំខ្មាស់ខកដល់ហើយមិនព្រមចូល នៅចាំគេត្រឡប់ទៅវិញ" ។

"ខ្ញុំអ្នក? សោភ័ក្រ្តបន្តពាក្យឡើង ។

"នរណាវិញបើដូច្នោះ?

"កុំបះឡេកឡួយដល់ខ្ញុំត្រីអ្នក អ្នកប្រាប់ស្រាប់ហើយ តើចិត្តថ្លើមរបស់ខ្ញុំដូចម្តេច ដែលថាខ្ញុំមិនចង់ចូលនោះ ខុសសោះប្អូន ពីព្រោះបណ្តាញឃើញពីរនាក់នេះ អ្នកដែលស្រឡាញ់ខ្ញុំអ្នកម្នាក់ទៀតនោះ គឺអ្នកហើយ មិនមែនឬ?

នាងចង់បដិសេធចេញ តែកំលោះនោះនិយាយតទៅទៀត ៖

"កុំដោះសាត្រីអ្នក ជាការឥតប្រយោជន៍ទេ ខ្ញុំដឹងចិត្តអ្នកអស់ហើយ អ្នកចាំទេពីល្ងាចថ្ងៃមុននោះ កាលដែលខ្ញុំមានអធ្យាស្រ័យ

ទុនលំពេងទៅ លើប្អូនយ៉ាងលើសលុប ប្អូនបែរជាបោះបង់ខ្ញុំ សេចក្តីស្នេហាចិត្តរបស់បងព្រាលចេញ នាំឱ្យបងខ្អែកចិត្តលែងសប្បាយពីថ្ងៃនោះដរាបមក" ។

ដោយពុំភ្ញាក់ខាត់តបមិនទាន់ សោភ័ក្ត្របានហៅខាងថា ប្អូនៗ ជួបពីដើមធ្វើឱ្យណាផនេត្រភ្ញាក់ខ្លួន រួមមុននាងទៀងស្ងាំង ចប្អូនចាត់ទៀតស្ងាយមួយពេច នាំឱ្យសោភ័ក្ត្រងឿងឆ្ងល់ពន់ពេក ឬមួយដោយស្ត្រីកាកគាប់គិតក៏ចេតល់ឈរដែលសេរីដល់អត្តាគតយ៉ាងមិនថិតខ្លួនទេដែរ? ទើបសោភ័ក្ត្រនិយាយបន្ថែមទៀតថា ៖

"ប្អូនអើយ បើបំណាច់ប្អូនគាត់អន់ចិត្តនឹងបងយ៉ាងណាក៏ ត្រូវតែប្អូនប្រាប់បងឱ្យដឹងខ្លួនផងអេះ នេះម្តេចក៏មកបែរខ្នងយ៉ាងនោះហើយផ្ទុះ នូវប្អូនណាផនេត្រ បងមិនបានគិតឡើយថា ហេតុនេះនឹងបែបនេះនឹងមានឡើងដល់រូបបងសោះ ។

មុខនាងកាន់តែស្រពោនចុះដាលំជាប់ រហូតដល់មិនស្រស់ខ្លួន ឆ្លើយតបដល់អ្នកផ្ទុះ នាងបានហុចដៃត្រជាក់ស្រេបទៅឱ្យសោភ័ក្ត្រ ចាប់ដៃនាងកំដៅហើយបានស្តាប់នូវសំដីយ៉ាងទន់ភ្លន់ផ្ទុះ

"បងខំស្វាហ៍អញ្ជើញមកលេងណា បងមានគុណនឹងខ្ញុំច្រើនណាស់ ខ្ញុំមិនភ្លេចទេពេញអស់មួយជីវិត" ។

រូបនាងត្រូវត្រាហ៍ចូលទៅក្នុង សោភ័ក្ត្រក៏គេចចេញមកផ្ទះវិញ ។

ណុជនេត្រូវកើតគ្រុនស្រៀវស្រាញ មមើមមាយលែងដឹងខ្លួនរហូតដល់សន្ធ្យាបានស្វាងគ្រាន់បើ ដើរចេញមកក្រៅបង្អួចក្រមាសូត្រស្រែបលើស្មា នាងរមៀងមើលព្រះការកះសន្ធ្យមលើមេឃ ឃើញផ្តុកៗ ម៉ាកៗដូចបងយំ ទើបនាងរន្ធត់ក្នុងចិត្តយ៉ាងខ្លាំងរហូតដល់ហៀរទឹកភ្នែកដោកមុខ បងស្រីរបស់នាងឃើញហើយក៏យកណាស់សាកសួរថា

"កើតអ្វីប្អូន មិនស្រួលខ្លាំងឬ បងទេចុះថ្នាំឲ្យញ៉ាំ" ។

"អរគុណណាស់ហើយបង ប្អូនគ្មានអ្វីទេ ដូចជាវិលមុខបន្តិច បងចូលទៅគេងវិញ" ។

បងស្រីក៏ក្រាក់នាងទៅកាន់គ្រែ ណុជនេតែហួសទ័ពដល់សោភ័ក្ត្រជាខ្លាំងតាញផ្ទុយជណ្ដប់ក្នុងខ្សែទ្រូងទុកជាទុក្ខ នាងនឹកដល់កាលដែលនាងធ្វើឲ្យសោភ័ក្ត្រកានគំនិតដើមទ្រូង ដោយគ្មានគេធ្វើអ្វីឲ្យចាំគុនសោះ នាងធ្វើឲ្យឈឺម៉ុងហើយស៊ូតែលះបង់ជីវិត ជួយស្រង់នាងទៀតទុបក៏សោភ័ក្ត្រ ខ្ញុំខុសបងនឹងបងសន្ទុកណាស់ ប្អូនមិនដឹងធ្វើដូចម្ដេចនឹងកែខុសកើត ... ។

នៅពេលជាមួយគ្នានោះ សោភ័ក្ត្រកំពុងអង្គុយមើលមេឃដែរ ពីព្រោះវត្តកាលជាទីគាប់ចិត្តនៃអ្នកនិរាសប្រាសចាករបស់ជាទីស្រឡាញ់ អ្នកមានសេចក្ដីសោកស្ដាយការអាឡោះអាល័យ អ្នកបានដល់ដែនស្នេហា

ជាវិធីដំបូងបង្អស់ ដោយមិនទាន់ដឹងចិត្តថ្លើមគ្នានៅឡើយ កាលបើគេ សំឡឹងមើលគ្នាភ្លេតហើយ អ្នកទាំងនេះក៏បានឃើញក្នុងមណ្ឌលពន្លឺខៀវ ភាពជាទីស្រឡាញ់របស់ខ្លួន ញញឹមមករកប្រមាទចំកម្មុខស្លូតស្រៀម រហូតដល់គំលាបទញ្ញថ្ងៃ តាមរឿងក៏តាមទ្រវត្តិនឹងចិត្តរបស់អ្នក នោះផង ពេលនោះ ប្អូនណាក៏សាសិងតែគ្នាទៅវិញទៅមក នាំឲ្យអ្នក សង្កេតបង់កាយខ្លួនទៅជាផ្កាយមួយដែរ ត្រូវគិតដល់សេចក្ដីក្ដៅក្រ-ហាយ ត្រូវគិតដល់សេចក្ដីពិត ត្រូវគិតពេលវេលា សោយទុក្ខបាន មួយគ្រា អ្នកដែលព្រាសចាកទៅ ហាក់ដូចជាវិលមកសមាគមជាមួយ ខុចផ្អៀងទិព្យនេះ ជាអ្នកល្អងលោមសត្វលោកទេតើ ជាអ្នកធានានា ពាក្យកំសត់ពីនេះទៅនោះ ជាអ្នកបន្តភ្ជាប់ជីវិតនៃគូស្រឡាញ់មួយគូ ៗ

សោកក្រៀបេញចាកគារស្រែមៃ · ពេលក្រោកមើលកនហាលឃើញ ដើមផ្កាកុឡាប ខានផ្កាតែមួយល្ហាសល្ងន់ត្រសៀកដោយខ្យល់ ទើប ស្រែកប្រៀបថា -

" នូផ្កាកុឡាបរីកតែមួយ
ជាត្រយបណ្ដូលនៃដីកំ
ក្រអូបឈ្ងុយឈ្ងប់ជាងអស់ផ្កា
" គួរឲ្យបេគនាថាក់ថមប៉ ៗ
បុប្ផាខ្ញុំអើយអ្នកចាំទុក

ពីនេះទៅមុខខ្ញុំមក្រី
តែផ្កាតែមួយក្នុងលោកិយ
ផលផុតទឹកដីពុំសាយ ។
ទុកផ្កាទៅកម្ទាំបំភ្លាត់
ឲ្យយើងប្រាសព្រាត់ឃ្លាតគ្នាឆ្ងាយ
បក្ខខ្ញុំនៅចាំពុំមានខណាយ
ផ្កានៅឋានឆាយខ្ញុំពុំស្បៀក ។
" មានតែអ្នកហើយកុំងឿងឆ្ងល់
ក្នុងដួងកមលផ្កាត់ជាប់ស្អិត
គាំងជាលំនៅទុំឋានស្ថិត
ជាគ្រឿសក្តិសិទ្ធនិរន្តរអើយ " ។

យប់នោះអ្នកទាំងពីរកែងទឹកផលគ្នាទៅវិញទៅមក មានបំណងតែមួយនឹងបានចួបប្រទាជាមួយគ្នាជារៀងៗ ។ ឯថ្ងៃដ៏ប្រសើរនោះមិនឲ្យអ្នកទាំងពីររង់ចាំយូរទេ ពីព្រោះសោកក្រៀមព្រួយចិត្តនឹងបណ្តាលបណ្តាច់ចិត្តមិនសប្បាយ ទើបដើរទៅសួរនោន់ពេលយប់ខែក្តីពីរថ្ងៃក្រោយមក ។

អ្នកទាំងពីរនាំគ្នាគន្លយលេងលើកៅអីវែងនៅមុខផ្ទះ ណុំផ្ទះនត្រ បានស្រស់ខួនមែនទែន តែមុខនៅពុំបានស្រស់ដូចដើម យូរៗ នាងផក

ដង្ហើមវែងម្ដងៗ ពេលនោះព្រះបន្ទូលតាបត្រៀមៗ ចេញចាកពាក្យស ម្ដុបសំឡី បន្ទោញស្មើស្រោងចុះតាប់ផ្ទាល់ណុផនេត្រតាំងគូនាងញញឹម ស្នេហ៍សោកក្រៃ ទ្រង់ដូចព្រួយផាំខ្លាំងតែបែបមិនបង់ថ្លៃផ្ទុកនោះប្រាប់ អរគុណ ស្នេហ៍យួបកំសាបសួនព្រះផ្ទាល់នាង ។

“ណុផនេត្រ” សោកក្រៃហៅនាងតិចៗ “ប្អូនចាំទេយប់ដួយមាន ទេក្ដីសួបយប់នេះ ប្អូនអង្គុយនៅលើកៅអីវែង ហើយបងអង្គុយនៅលើ កៅអីតូចបៀតប្អូនៗ បានទំរើយាយតេកបងដូចេះ “ផ្ទៃលបង់ជាកំព្រាម៉ង់ៗ ទាក់ឯងនោះមិនមែនទេព្រោះណុផនេត្រនៅ៖ខ៖ ...” ប្អូនទឹកឃើញទេ ពាក្យប៉ុណ្ណឹងហើយប្អូន ដែលនាំឲ្យបងគ្រាំទុក្ខវេទនាតស៊ូផល់ជីវិតរហូត មក សេចក្ដីសុខរបស់បង មានតែកងរន្ធុបពីឈាណូគប៉ុណ្ណោះ ដោយ ហេតុអ្វីបានជាប្អូនរកតាំទ្វីសេចក្ដីសង្ឃឹមចេញពីទ្រូងបងមិនគួណាគតាស្បូរ វល់បងផង ។

ក្នុងវេណៈនោះ មុខរបស់នាងកាន់តែស្លាំងឡើង បបូរមាត់ឡើង ស្វាយមួយរំពេច ផ្អែកខ្លួនទល់ទៅនឹងកៅអីយ៉ាងស្រងូតស្រងាត់ មាន សេចក្ដីប្រៀបផ្ទៃយកួហៅកាត់ទៅ នាំឲ្យនាងព្រឺព្រួចញាប់ញ័រខ្លួន ។

“ប្អូន! ប្អូនមេត្តាប្រាប់បងឲ្យដឹងផង តើបងធ្វើអ្វីឲ្យខ្លាចគ្នាដល់ប្អូនខ្លះ បានជាប្អូនផ្លាស់ចិត្តបក្ខក្លាយមួយរំពេច?

ណុជនេត្រងើបមុខឡើង បបូរមាត់ញ័រទទ្រើក នាងខំធ្វើយ៉ាងខ្លាំងស្ទើរទ័ងខ្សឹបថា៖ "បងកុំសួរប្អូនធ្វើអ្វីដូចជានាំទុក្ខមកឲ្យប្អូនវិញទេ បងគ្មានធ្វើអ្វីឲ្យប្អូនអន់ចិត្តទេ តែ ... តែ ... ។

"កុំសួរប្អូនធ្វើអ្វីបង ... " ។

"ឱប្អូនអើយ ! បើប្អូនមិនប្រាប់បងឲ្យដឹងផង ធ្វើម្តេចបងនឹងដឹងបំណៃកកង់នេះ បងមានចិត្តប្រតិព័ទ្ធលើប្អូនជាខ្លាំង ដែលបងលែងឲ្យផុតពីប្អូនទៀតនោះមិនមែនដោយបងអស់ចិត្តលែងស្រឡាញ់នោះទេ គឺដោយសេចក្តីភ្លុកសង្ស័យប៉ុណ្ណោះទេតើ ឱណុជនេត្រជន់បងអើយ សេចក្តីខ្លាចគ្រប់សង្កត់មាត់បងមិនឲ្យនិយាយទេ តែពេលនេះបងអត់ទ្រាំពុំបាន សូមឲ្យប្អូនសន្តោសបងផង បងសូមលន់តួថាបងស្រឡាញ់ប្អូនស្មើជីវិត ជាសេចក្តីស្រឡាញ់ដ៏ស្មោះត្រង់ មិនមែនដោយសារសម្បត្តិប្រយោជន៍អ្វីមួយ" ។

ស្លូនាងដកដង្ហើមវែងបង្អាក់ឲ្យលោកក្រឈប់មួយស្របក់ ។

"បងដឹងហើយប្អូន ខ្លួនបងនេះប្រៀបដូចសត្វក្អែក មិនគួរបើប្រាថ្នាលើរូបប្អូនជាពូជហង្ស តែនេះដោយសេចក្តីស្រឡាញ់ខ្លាំងណាស់" ។

"ពិតឬ? ណុជនេត្រសួរឡើង ។

«ចុះប្អូននៅសង្ស័យត្រង់ណាទៀត បើប្អូនមិនជឿចិត្តនោះ បងនឹងសុំផែនឲ្យឃើញត្រង់ប្រការតាមសេចក្ដីបង្គាប់របស់ប្អូន» ។

«ខ្ញុំដូចជាឮគេនិយាយថា ដល់ខែកត្ដិកបងនឹងរៀបការជាមួយនឹងកូនចៅខ្សែស្រឡាយ ឬជាមិនពិតទេ?

«ពិតដូចជាគេនិយាយមែនហើយប្អូន» ។

«បើដូច្នេះ ពាក្យដែលបងមានប្រសាសន៍តាំងពីមុននោះ មិនជាពាក្យមុសាទេហើយឬ?

«ទេប្អូន, ចិត្តរបស់បងនៅក្នុងកណ្ដាប់ដៃប្អូនតាំងពីថ្ងៃដំបូងដែលបងបានឃើញប្អូនមក ឯទីគេនាំឯណាដណ្ដើមយកពុំបានឡើយ គឺថាប្អូនជាស្រ្ដីយកចិត្តរបស់បង ដែលបងព្រមទទួលកូនចៅខ្សែស្រឡាយជាគូ នោះគឺដោយសេចក្ដីបង្ខំដោយសេចក្ដីគោរពសន្ដានគុណ តែបងគ្មានចាប់ចិត្តនឹងនាងនោះ ដល់តិចតួចឡើយ តាំងពីបងកើតមកព្រោះនឹកប្អូនពេក គេក៏ដែលរកចាប់អាចបង់រហូតដល់សព្វថ្ងៃនេះ បងនឹងនាងនោះគ្មានទាក់ទងអ្វីនឹងគ្នាទៀតទេ ឲ្យប្អូនជឿចុះ» ។

«រឿងហ្នឹងក៏គួរលើកលែងចុះ តែបងចាំទេកាលចូលឆ្នាំថ្មីបងបានប្រៀនដូចម្ដេច ប្អូនចាំជាក់ត្រង់ថានេះ:

«ធម្មតាបុប្ផាតែងតែរោយរាយ

ខាត់ខាយឃ្លាតឆ្ងាយចាកចេញពីទង

តែមានក្រពុំលាស់ទៀនចំព្រង

តែល្អកន្ទន់ន្ទួរឲ្យស្នេហា."

. . . . . . . . . . . . . . . . .

"ព្រោះយើងនៅក្មេង កោងតែគិតគាន

"កេឲ្យកុំផាន កុំស្តាយបាស់ពើយ" ។

គេបានសេចក្ដីជួបមួយ ក្រែងមិនឲ្យកាក្មោះពេកពើយ ដល់កា-រម្មណ៍ណា ដែលមិនបានទទួលឬ គឺយើងមិនត្រូវតែសួរទេ បើចាស់មិនគេកកោងកូថី មិនមែនដុំតាសុងណា ទំងបានតែមួយក្មេងក្មេង កំពងអន្ដីមាន ទុកពាក្យកំព្រោះសុទ្ធតែមិនពិតឬ ចិត្តក៏មិនទៀង !

"អត់ទោសប្អូន ! ដែលប្អូនមានប្រសាសន៍ចាំងប៉ុន្មាននោះ គឺថាប្អូនបានស្ដាប់បងព្រៀងនៅពេលនោះដែរ ចុះប្អូនចាំទេ បងសូមសួរប្អូនមួយពាក្យដែលប្អូនបានសាសងមួយទឹកទាត់ពាក្យកាលពេលនោះថា "ដឹងតែខ្ញុំមិនបានថាស្ដាប់ដែរ តែមើលទៅប្រហែលជាមិនពិតទេ " បើដូច្នោះប្អូនមិនកុំហាកកាត់ពាក្យហើយកងពេលនោះ ?

"ចាះទេ នឹងត្រូវបៀតពេក ព្រោះក្នុងពេលនោះគាតសួរគ្រូក្រៅពីចំរៀងរបស់បង" ។

"ដូច្នេះឬ ? ក៏ឯពាក្យបងព្រៀងនោះ គឺដូច្នោះដែរ ចាត់បងថាមិនទីកគាតែចិត្តពេះតែរកមិនដាច់ ព្រោះដំណោដែលជុះក្នុង

ដើមទ្រូងនោះ មិនមានទេសេចក្ដីទន់តែបាន គឺជាចិត្តទន់មាត់ស្រពោន ដូចគ្នានេះ ឲ្យប្អូនជឿចុះ...។

«ប្រែថា បងនឹកក្នុងចិត្តដូច្នេះ ខុសជាខ្ញុំបងសេពមិនចូលសេចក្ដីសន្តោសរបស់បងដូចម្ដេចក្ដី ខ្ញុំនៅតែមានចិត្តខ្លោចផ្សាលើស ឬមួយមកដល់បងជាដកចប្ដី? ប្អូនបងទឹកឲ្យព្យាសារ៉ាវត្រង់នេះ។

សោភ័ក្ត្រខ្ញុំគុះគំនិតឈប់ផ្សាញ៉ីនមួយស្របក់ បានឆ្លើយតបទៅនាងវិញថា

«ប្អូន បងមិនគិតដូច្នោះទេ បងដឹងជាក់ហើយ ថាប្អូនមិនរំលងបង ដែលបងមានសំណាងបានជួបមុខប្អូនពេលនេះ ក៏ព្រោះបងបានជួយស្រង់ប្អូនជំនោះ ទន្ទឹងឲ្យបងយល់អ្វីម្ល៉េះហ្ន៎? ម្ដេចក៏អកញ្ញម្ល៉េះ ជាតិនេះ ឃ្លាតឆ្ងាយពីម្ដាយឪពុកប្អូន គ្មានគេរាប់អានក្នុងលោកនេះ តើអ្នកក្រាស់ម្ល៉េះទៅគាតអើយ»។

ទឹកភ្នែកហូរស្រោចមុខសោភ័ក្ត្រ នាងឃើញហើយក៏ខឹតអាណិត ខ្លោចចិត្តពន់ក្រាយបង្អស់សោភ័ក្ត្រសួរនាងទៀតថា៖

«ណ្ហើយចុះប្អូន បងសូមសួរប្អូនជាលើកក្រោយបំផុតលែងសួរទៀត ហើយបងនឹងលែងមករកគួនប្អូនទៀត តើប្អូននៅតែស្អប់ខ្ពើមបងឬ?

នាងងើបមុខមើលសោភ័ក្ត្រ ហើយញញឹមបក់ក្រៀមក្រវីក្បាល ទំនងបដិសេធសោភ័ក្ត្រចាប់ដៃនាងសួរឡើងទៀតថាៈ

" ពិតឬ ! ណាងនេត្រមាសបង ? "

នាងនៅស្ងៀមមួយស្របក់ ហើយញញឹមមិនតប តែសោភ័ក្ត្រមើលក្នុងភ្នែកនាងបានសេចក្ដីថា នាងមិនស្អប់សោភ័ក្ត្រទេ ហើយបើមិនស្អប់គ្មានអ្វីក្រៅអំពីស្រឡាញ់ពេញចិត្ត ទើបសោភ័ក្ត្រត្រេកអរស្រែកៗ តានឡើងៈ

" ឱមេឃ ! អ្នកងងឹតចុះ ព្រះបន្ទូលក់តន្ទុំ ព្រះភាពសាបសូន្យពីអាកាស ភ្លៀងផ្គរលាន់ត្រហឹមតាមចិត្ត ខ្ញុំលែងតោកញញើតលែងព្រឺព្រួចភិតភ័យហើយ ព្រោះអារម្មណ៍ជាទីពេញចិត្តរបស់ខ្ញុំនោះ ខ្ញុំគាប់ចិត្តអាស្រ័យបានហើយ ឲណាជានេត្រផងបងអើយ គ្មានថ្ងៃណាដែលបងបានរីករាយសប្បាយក្នុងចិត្តជាងថ្ងៃនេះទេ " ។

ឡុះដោយសេចក្ដីសប្បាយដ៏លើស សោភ័ក្ត្រយកចិត្តទុកបួលពិត នាងហានយកដៃអង្អែលស្មារបស់នាង ហើយកន្ទ្រាន់ជាប់ទន់ដើមទ្រូង ថ្ពាល់អត់តាំងពីកើតមកសម្ញែងក្រោយរាងស្អិត នាំឲ្យស្រៀវព្រឺក្រើបស្រៀបស្រាលត្រេកត្រអាលពន្លឺតសេចក្ដីសុខក៏ជាប់បួលដល់បេះដូងអ្នកទាំងពីរនាក់នោះ ទើបសោភ័ក្ត្រខ្សឹបៗ ទន់ត្រចៀកនាងថាៈ

"ប្អូនៗ បងស្រឡាញ់ប្អូនណាស់ រកអ្វីប្រៀបផ្ទឹមផងពុំបាន ស្រ-ឡាញ់តែណុជនេត្រតែមួយជាត្រួយបណ្តូលជីវិតរបស់បង" ។

ណុជនេត្រឮហើយក៏ញាក់ខ្លួន ដោយរំភើបពីការឱបរឹតនៃគូស្រ-ឡាញ់របស់នាង ដោយនាងនឹកអៀនខ្លួនមិនគួរនឹងបណ្តោយខ្លួនឲ្យផ្ដលសោះ សោភ័ក្រ្តក្រាក់ខ្លួនបែរមើលមុខនាង ក៏ឃើញទឹកភ្នែកនាងចេញសន្សើមៗ មកលើថ្ពាល់នាងទាំងគូ សោភ័ក្រ្តអង្អែលកដៃនាងយ៉ាងថ្នម នាងក៏សន្សើមៗ ញាក់យំ" ។

ពន្លឺមួយបញ្ចាំងភ្លើងបរពត់មុខនោះទៅឆ្ងាយ សត្វឆ្មាយំញ៉ាវៗកេឡានៅជិតនោះ សុនខព្រុសអួតដើរខ្លាំងៗ សត្វប្រចៀវហើរកាត់ផ្សេងហោះទៅឆ្ងាយទៅ ព្រះចន្ទត្រូវពពកបាំងពេលៗ តែសោភ័ក្រ្តមិនបានចាប់ភ្លឹក ព្រោះគ្រានោះដឹងថា នៅជិតណុជនេត្រហើយមានសេចក្តីប្រាថ្នាលើរូបនាងតែមួយប៉ុណ្ណោះ ដោយមានសេចក្តីសង្ស័យនៅឡើយ ទើបសាកសួរនាងម្តងទៀត

"ប្អូនបាត់ស្អប់ខ្ពើមបងហើយឬនៅ?

"កុំសួរខ្ញុំពីរឿងនេះទៀតបង" ។

"ប្អូន! បងស្រឡាញ់ប្អូនណាស់ហើយបានជាសួរ ម្តេចក៏ប្អូនមិននិយាយពាក្យមួយម៉ាត់ឲ្យបងសុខចិត្តផង ។

៖ នាងនៅតែស្ងៀមមុខកាន់តែក្រៀមឡើង ” ។

“ ណុជទ្រ . . . ។

នាងខ្សឹកខ្សួលរំជួលចិត្តហើយឆ្លើយឡើងយ៉ាងគាក់ស្លុតថា: “បងកុំ . . . កុំព្រួយថាស្រីរូបប្អូនធ្វើឲ្យប្អូនមិនចង់នៅទេ    ពីព្រោះក្នុងចិត្តប្អូនណាស់” ។

ប្អូន . . . ស្រឡាញ់បងណាស់ដែរ ឲ្យបងជឿចុះ តែ . . . តែ . . . ប្អូនស្រឡាញ់ត្រឹមចិត្តបងប៉ុណ្ណោះ ធ្វើម្ដេច . . . កម្មរបស់យើង . . . ។

នាងស្ទុះឱបសោភ័ក្ត្រដាក់ក្បាលលើដើមទ្រូងកំលោះ យំជាប្រចែ សោភ័ក្ត្រយកដៃអង្អែលសក់ខាងក្រោយមក ចុងបំផុតនាងងើបឡើងរួចលាសំឡាញ់បណ្ដើរយំបណ្ដើរ យកកូនកន្សែងជូតភ្នែកដើរចូលទៅក្នុងទៅ ទុកសោភ័ក្ត្រឲ្យនៅស្រឡាំងកាំងតែម្នាក់ឯង ។

*

*     *

(មានត)

ឯកសារមហាស្រាក្រី

មួយពាន់មួយយប់ (ជារឿងអារ៉ាប់)

ភាគទី ១២

លោកឌុយ-ប៊ុនស្នូរ ប្រែចេញពីភាសាបារាំងសែសមកជាខេមរភាសា

(តមក)

---

## ដំណើរទី ២ របស់សិនបាដអ្នកដើរសមុទ្រ

ដូចជាខ្ញុំបានពណ៌នាជំរាបអស់លោកពីថ្ងៃម្សិល ខ្ញុំប៉ងនឹងប្រមូលទប់ចិត្តឱ្យមូល ហើយឈប់ទៅណាមកណាទៀតហើយ, ប៉ុន្តែមិនយូរប៉ុន្មាន ខ្ញុំមានសេចក្ដីធុញទ្រាន់អផ្សុកដោយខ្ញុំទំនេរពេក, គំនិតដដែល ក៏តាំងមកដុះផ្ដើមតាមកំណើតក្នុងចិត្តរបស់ខ្ញុំសាជាថ្មីទៀត គឺគំនិតចង់ធ្វើដំណើរលក់ដូរដូរប្រែតាមសមុទ្រ ។ ខ្ញុំតាំងគិតពាញ់រៀបចំទិញទំនិញ ហើយខ្ញុំទៅសេពគប់នឹងពួកឈ្មួញខ្លះ ដែលខ្ញុំដឹងជាក់ច្បាស់ថាមានចិត្តទៀងត្រង់ល្អ ។ យើងនាំគ្នាជ្រើសរើសជួលបានសំពៅមួយស្អាតហើយមាំ, រៀបពិធីសែនព្រេនរួចស្រេច យើងលើកក្ដោងបើកចេញទៅអំពីក្រុងបាល់ស្សូរ៉ា ។

យើងឈប់ចតហូរហែតាមកោះច្រើន ហើយលក់ដូរបានចំណេញដូចចំណង, ថ្ងៃមួយយើងឡើងលេងលើកោះមួយ ដែលមានរុក្ខជាតិ

គ្រប់តែបសម្បូរដោយផ្លែដេរដាស ប៉ុន្តែស្ងាត់ឈឹងមិនប្រទះឃើញផ្ទះមួយឬមនុស្សម្នាក់សោះ, យើងបាននាំគ្នាទៅអង្គុយលេងយកខ្យល់អាកាស តាមមាត់ព្រែកដែលហូរកាត់កាលធំ ។

អ្នកខ្លះដើរបេះផ្កាលេង, អ្នកខ្លះទៀតឡើងបេះផ្លែឈើបរិភោគ ចំណែកខាងខ្ញុំយកក្រុមនាហារនិងស្រាទំពាំងបាយជូរ ទៅពួនសម្ងំស៊ីផឹកតែម្នាក់ឯង នៅមាត់ព្រែក ១ មានម្លប់ត្រឈឹងត្រឈៃ ។ លុះបរិភោគឆ្អែតស្កប់ស្កល់ហើយ ទើបខ្ញុំប្រះខ្នងពាលសន្ធឹងលើស្មៅ ហើយទទួលបានដំណេកលក់ស៊ប់ទៅ, កាលខ្ញុំភ្ញាក់ឡើង ស្រាប់តែសំពៅចេញចោលខ្ញុំបាត់ មើលពីចម្ងាយឃើញតែក្ដោងលិមៗ ។ សូមអស់លោកអ្នកនឹកពិនិត្យមើលចុះ សេចក្ដីទុក្ខរបស់ខ្ញុំធំយ៉ាងណាទៅ! ខ្ញុំគិតថាខ្លួនខ្ញុំប្រហែលជានឹងដល់នូវសេចក្ដីក្សិណក្ស័យជីវិតក្នុងគ្រានេះហើយ ទើបខ្ញុំស្រែកទ្រហោយំទះតប់ក្បាលផ្ដួលខ្លួនទៅនឹងដី ទាក់ទាញសក់ខ្លួនសោកសៅទោមនស្សក្នុងចិត្តតែម្នាក់ឯង ដោយនឹកស្ដាយណាស់ មិនគួរបើធ្លាយគំនិតមកជួបប្រទះនឹងសេចក្ដីទុក្ខនេះទៀតសោះ តែខ្ញុំគិតឃើញភ្លាមថាសេចក្ដីស្ដាយក្នុងពេលនេះជាការឥតប្រយោជន៍ ហើយមិនត្រូវពេលវេលានឹងនឹកក្នាណោបអាធម៌អ្វីឡើយ ។

ខ្ញុំនឹកបន់ស្រន់ដល់ព្រះអង្គ, ព្រោះខ្ញុំមិនដឹងជានឹងដោះស្រាយខ្លួនយ៉ាងណាទៅទៀត ខ្ញុំក៏ឡើងលើដើមឈើមួយដ៏ខ្ពស់ សង្កេត

មើលគ្រប់ទិសទៅក្រែងលោបានជួបប្រទះនឹងអ្វីគ្រាន់ជាទីពឹងសង្ឃឹមតក់ក្ដៅ ក្រឡេកមើលទៅក្នុងសមុទ្រឃើញតែមេឃនឹងទឹកជាប់គ្នាល្វឹងល្វើយ តែនៅខាងផែនដីក្បែរមាត់ច្រាំង ខ្ញុំបានមើលឃើញដុំអ្វីមួយសៗ ខ្ញុំប្រ-ញាប់ប្រញាល់ចុះពីដើមឈើមកហើយ ប្រមូលស្បៀងដែលនៅសល់បន្តិចបន្តួចដើរតម្រង់ទៅរករបស់សៗនោះឯង ដែលមើលពីចម្ងាយទៅមិនដឹងជាអ្វី ៗ

កាលដែលខ្ញុំបានទៅដល់ជិតបន្តិចហើយ ខ្ញុំសំគាល់ថាជាដុំមួយមូលធំសន្ធឹក; លុះទៅដល់ជិតខ្ញុំស្ទាបទៅទន់ៗ ខ្ញុំក៏ដើរក្រវែលជុំវិញដើម្បីរកមើលផ្លូវចូល ប៉ុន្តែឥតឃើញមានប្រហោងដល់តិចតួចសោះ ខ្ញុំបង្អង់ឡើង ៗ មិនកើតព្រោះរអិលពេក; ដុំនោះមានទំហំជុំវិញប្រវែងហាសិបជំហាន ៗ

ពេលនោះ ព្រះអាទិត្យជ្រៀងជ្រេទទាបទៀបអស្តង្គត, មេឃមីស្រទំហាក់ដូចជាគេពួតសោកបាំងបិទជិតទាំងអាកាស ទើបសត្វស្លាបមួយធំក្រៃណាទំនង ហើរតម្រង់មករកទីដែលខ្ញុំឈរនោះ ខ្ញុំបាននឹកឃើញដល់ឈ្មោះសត្វមួយ ដែលហៅថាសត្វអន្ទ្រី ហើយសំគាល់បានថាតែមូលសធំនោះ ជាពងរបស់វា ៗ មិនយូរប៉ុន្មានបក្សីបន្ទាបខ្លួនចុះមកក្រាបលើពងវា, ឯខ្លួនខ្ញុំឈរប្រចៀតជិតពងប្រកិតទទឹងជើងសត្វបក្សីនោះឯង ៗ ខ្ញុំកាត់យកឈ្នួតក្បាលចងភ្ជាប់ខ្លួនខ្ញុំទៅនឹងជើងសត្វ

ដោយមានសង្ឃឹមថា ព្រឹកស្អែកវានឹងហើរចាកចោលសំបុកទៅ ហើយនឹងនាំចាំងខ្ញុំឲ្យបានរួចចេញពីកោះនោះពុំខាន; ពិតដូចគំនិតដែលខ្ញុំគិតមែន ព្រលឹមឡើងបក្សីហើរចេញចាកពងទៅតាមអាកាសខ្ពស់ត្រដួច នាំចាំងខ្លួនខ្ញុំជាប់ទៅជាមួយផង ហើយស្រាប់តែហោះពួយលឿនស្ទុះចុះដល់ដីភ្លាម; ខ្ញុំក៏ស្រាយចំណងយ៉ាងប្រញាប់ ហើយបក្សីនោះស្ទុះទៅចឹកពាំពស់ ១ មានបណ្ដោយខ្លួនវែងលៃលៃ រួចទទះស្លាបហើរចេញពីទីនោះទៅវិញ ។

កន្លែងដែលសត្វស្រឡាកខ្ញុំចោលនេះ គឺជាជ្រោះប្រកបយ៉ាងជ្រៅ មានភ្នំព័ទ្ធជុំវិញ ហើយភ្នំទាំងនោះខ្ពស់ណាស់ មើលដាច់កន្ទុយភ្នែក ហើយចោតស្ទើរតែឡើងទៅលើកំពូលពុំរួចឡើយ ។ ដំណើរនេះនាំឲ្យខ្ញុំតឹងទ្រូងតុះតុញពាល់គំនិតអស់; បើប្រសិនជាយកកោះស្លាកនោះមកធៀបនឹងជ្រោះនេះ ឃើញថាខ្ញុំឥតបានធូរទ្រូងប៉ុន្មានទេ ព្រោះជាទីប្រកបដោយទុក្ខលំបាកដូចគ្នា ។

នៅក្នុងជ្រោះនោះ ខ្ញុំពិនិត្យឃើញគ្រាប់ពេជ្រដេរដាសពាសពេញទាំងដី ហាក់ដូចជាគេយកមកចោល, ខ្ញុំក៏មានសេចក្ដីត្រេកអរសប្បាយចិត្ត, ប៉ុន្តែមិនយូរប៉ុន្មាន ខ្ញុំក្រឡេកមើលពីចម្ងាយឃើញពស់ធំៗហើយវែងៗ ដែលគួរតែនឹងលេបដំរី ១ បានដោយងាយ ។ ពេលថ្ងៃពស់ទាំង

នេះចូលជ្រកពួនក្នុងរូងជ្រៅ បង្ការកុំឲ្យសត្វឥន្ទ្រីគេឃើញ ពេលយប់ក៏នាំគ្នាចេញមករកស៊ីរើសរណ្ដូ ។

ថ្ងៃនោះខ្ញុំគិតតែដើរលេងពាសពេញតែកោះ ហើយឈប់សម្រាកក្រោមដើមឈើដែលស្អាតល្អ, កាលព្រះអាទិត្យទន់ទាបអស្តង្គតទៅហើយ ខ្ញុំបានគយគន់ឃើញរូងមួយ ដែលគួរនឹងទទួលបានដំណេកបណ្ដោះអាសន្នបានដោយស្រួល ឥតមានគ្រោះថ្នាក់អ្វី ខ្ញុំក៏ចូលក្នុងរូងនោះហើយយកថ្មជុំជួយដុំបិទមាត់រូង រួចខ្ញុំបរិភោគស្បៀងតែបន្តិចបន្តួច ។ ខាងក្រៅពស់លូនរកស៊ី, សូរសើពួសំឡេងកុះធ្វើឲ្យខ្ញុំភិតភ័យញ័រអស់ទាំងខ្លួន ខ្ញុំខំប្រឹងដេកបិទភ្នែក ប៉ុន្តែទទួលបានដំណេកមិនលក់សោះ ។ លុះដល់ព្រឹកព្រាងស្វាងព្រះសុរិយារះឡើង ពស់តែចូលរូងអស់ ទើបខ្ញុំចេញពីរូងញញើតញញ័រដើររកគ្រាប់ពេជ្រយូរណាស់ ឥតមានចិត្តត្រេកត្រអាលនឹងរើសសោះ, អស់កំលាំងខ្លាំងពេក ខ្ញុំឈប់សម្រាកបរិភោគអាហារដែលសល់នៅ ហើយក៏ផ្ដាំងស្មារតីដេកលក់ទៅ ។ មិនបានលក់បានយូរប៉ុន្មានផង ស្រាប់តែមានវត្ថុអ្វីមួយធ្លាក់ឮសូរព្រុះមកក្បែរខ្លួនខ្ញុំ, ខ្ញុំភ្ញាក់បើកភ្នែកឡើង ឃើញសាច់ស្រស់ ១ ដុំធំ ។ ក្នុងពេលនោះ ឃើញមានដុំសាច់ជាច្រើនទៀត ធ្លាក់បន្តៗគ្នាមកពាសពេញទាំងកោះ ។

ខ្ញុំបាននឹកឃើញដល់រឿងកំសាន្តចិត្តមួយ ដែលពួកឈ្មួញសំពៅតែងនិយាយពីជ្រោះពេជ្រ ហើយនឹងសេចក្ដីប៉ិនប្រសប់របស់ពួកឈ្មួញដើម្បីនឹងទាញយកពេជ្រពីក្នុងជ្រោះនោះឯង ។ ពួកឈ្មួញប្រើកិច្ចឧបាយយ៉ាងនេះ គឺក្នុងរដូវដែលសត្វឥន្ទ្រីញាស់កូនវារួចហើយ វាតែងហើរត្រាច់ទៅក្នុងជ្រោះ ដើម្បីរកអាហារយកទៅឲ្យកូនវាបរិភោគ, ពួកឈ្មួញបបួលគ្នាឡើងបោះជម្រំលើកំពូលភ្នំ តាំងរៀបពិធីសម្លាប់សត្វពាហនៈ គេពន្លះយកសាច់ជាដុំធំៗ ហើយបោះទម្លាក់ទៅក្នុងជ្រោះនោះធ្លាក់ពារប្រទះទៅលើគំនរពេជ្រ ។ ពេជ្រមុតជាប់នឹងដុំសាច់នោះឯង, ឯសត្វឥន្ទ្រីបានឃើញដុំសាច់ដូច្នោះ ក៏ហើរចុះទៅចាប់ពាំយកទៅឯសម្បុក ដើម្បីជាអាហាររបស់កូនវា ។ ពួកឈ្មួញដែលបានប្រចាំសម្បុករៀងៗខ្លួនទុកជាមុន រត់ទៅស្រែកបង្អើល ។ បក្សីផ្អើលហើរចេញពីសម្បុកបាត់ទៅ គេក៏ឡើងទៅលើសម្បុកហើយប្រឡេះយកគ្រាប់ពេជ្រ ពីដុំសាច់នោះបានដោយស្រួល ។

កាលនឹកឃើញដល់រឿងនោះហើយ ខ្ញុំមានសេចក្ដីសង្ឃឹមយ៉ាងមាំ ទើបខ្ញុំប្រឹងរកគល់ឧបាយនឹងចេញពីជ្រោះនោះឲ្យរួច ខ្ញុំក៏ដើររើសយកដុំពេជ្រណាដែលធំៗហើយល្អផង ដាក់ពេញក្រេបោចស្បែក ១ ដែលខ្ញុំបានយកជាប់តាមខ្លួនមកសម្រាប់ដាក់អាហារបរិភោគ រួចខ្ញុំជ្រើសរើសមើលដុំសាច់ណាដែលធំហើយវែងជាងគេ ខ្ញុំយកឈ្នួតក្បាលរបស់ខ្ញុំ

ចងរួតរឹតខ្លួនខ្ញុំភ្ជាប់ទៅនឹងដុំសាច់នោះ ហើយខ្ញុំផ្ដេកខ្លួនផ្កាប់មុខទៅនឹងដី, ក្រវាត់ស្បែកចងភ្ជាប់នឹងខ្សែក្រវាត់ខ្ញុំ ដើម្បីកុំឲ្យជ្រុះ ។

មិនយូរប៉ុន្មាន ស្រាប់តែសត្វឥន្ទ្រី ១ ហើរចុះទៅចាប់ពាំយកដុំសាច់នោះទៅ នាំទាំងខ្ញុំយកទៅដល់លើកំពូលភ្នំហើយដាក់ក្នុងសម្បុកវា ពួកឈ្មួញនាំគ្នាស្រែកសន្ធាប់បន្លឺសត្វនោះ ឲ្យរត់ហើរចៀសចេញទៅឆ្ងាយ ។ ឈ្មួញម្នាក់ដើរត្រង់មកសម្បុកដែលខ្ញុំនៅនោះ, កាលឃើញខ្ញុំហើយឈ្មួញនោះ ហាក់ដូចជាភ្ញៀងឆ្ងល់ក្ដុកក្ដាំង; លុះមកដល់ជិតខ្ញុំហើយ គេមិនមានគិតសាកសួរអំពីរឿងរ៉ាវ ដែលខ្ញុំបានមកនៅលើសម្បុកនោះសោះ បែរជាពោលប្រកាន់ចាប់ទោសថា ខ្ញុំលួចគ្រាប់ពេជ្រពីសម្បុករបស់គេទៅវិញ ។ ខ្ញុំក៏និយាយលួងលោមថា "កាលណាអ្នកបានជ្រាបរឿងរ៉ាវរបស់ខ្ញុំជាក់ច្បាស់ហើយ អ្នកនឹងមានសេចក្ដីអាណិតមេត្តាដល់ខ្ញុំពុំខាន សូមអ្នកស្ងៀមស្ងាត់ទៅ ខ្ញុំមានគ្រាប់ពេជ្រគប់គ្រាន់ល្មមសមគួរ នឹងចែកគ្នាពីរនាក់បាន ឥតមាននរណាបានស្មើឡើយ, ឯពេជ្ររបស់ខ្ញុំទៀតសោត សុទ្ធសឹងតែជ្រើសរើសសម្រាំងយ៉ាងអស់ពីចិត្ត ពីក្នុងជ្រោះនោះមក" ។ ឈ្មួញឯទៀតបានឃើញខ្ញុំ ក៏តែឈូឆរជុំវិញខ្ញុំ មានសេចក្ដីងឿងឆ្ងល់ណាស់ ព្រោះគេឃើញខ្ញុំនៅទីនេះ ហើយរឿងរ៉ាវរបស់ខ្ញុំដែលបាននិយាយប្រាប់គេនោះ គេរឹតតែមានសេចក្ដីងឿងឆ្ងល់ថែមទៀត, គេនាំគ្នាសរសើរខ្ញុំហើយសោកនឹង

(មានត)

# ព្រះរាជប្រវត្តិ

## ព្រះបាទសម្តេចព្រះជ័យជេស្ឋា (ព្រះអង្គស្ងួន)

ហ្លួងឧត្តមមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

ដល់ថ្ងៃ ១១ កើតខែបុស្សឆ្នាំជូតនព្វស័ក (ព. ស. ២២៤១) ស្តេចត្រាស់បង្គាប់មន្ត្រីខ្ញុំរាជការ ឲ្យរៀបពិធីរាជាភិសេកមង្គលនៅព្រះតំណាក់ថ្មី រួចត្រាស់និមន្តព្រះរាជាគណៈចំរើនព្រះពុទ្ធមន្ត ៧ ថ្ងៃតាមប្រពៃណី ទ្រង់ព្រះមេត្តាប្រោសតាំងព្រះអង្គ (អឹម) ជាសម្តេចព្រះកែវហ្វា ។ រួចស្តេចទ្រង់ផ្សំនឹងសម្តេចព្រះមហាក្សត្រីជាព្រះរាជបុត្រីរបស់ព្រះអង្គឲ្យជាអគ្គជាយាសម្តេចព្រះកែវហ្វា ។

## ព្រះបាទសម្តេចព្រះជ័យជេស្ឋា ទ្រង់លើកព្រះទ័ពថ្មីទៀត

ថ្ងៃមួយ ស្តេចព្រមដោយព្រះអគ្គមហេសី ព្រះស្នំនឹងសេវកាមាត្យ ខ្ញុំរាជការប្រុស ស្រី គប់ក្រុម ព្រះរាជដំណើរចេញទៅប្រពាតឯតំបន់ក្រាំងល្វាខែត្រកំពេញ ស្តេចគង់ព្រះរាជរថទឹមគោ ។ សកករាជគីគោព្រៃ ចៅពញាតេសេនាបព្រះទីនាំង ខុនញ៉ាណាវគ្គជិះសេះបរហោមមុខព្រះទីនាំង មន្ត្រីខ្ញុំរាជការជិះសេះជាគូៗហែអមព្រះទីនាំង សេនាបតីជិះសេះហែមុខបន្ទស់ មន្ត្រីស័ក្តិ ៨-៨ ហ៊ុំពាន់ជិះរទេះ ហែខាងក្រោយ ចន ត្រដោតកណ្តឹងបន្ទន់ពួស័ពគ្រំពានព្រៃ ។

លុះស្តេចយាងទៅដល់ភូមិក្រាំងល្វា ស្រះហាវៃពេញពក្ត្រ នោះម៉ែស្រួសជាប្រពន្ធពញាជ័យ ជាខ្ញុំពរការបាសពីសម្តេចព្រះកេដបិតា នាំកូនក្រមុំឈ្មោះនាង ពៅ អាយុ ១៦ ឆ្នាំទៅជញ្ជាត់ត្រៃ ពុំដឹងជាស្តេចយាងមក ។ លុះឃើញស្តេចគង់ព្រះទីនាំងមកដល់ទីជ័យបេញពុំទាន់ ទើបនាំកូនក្រមុំគេចយចុះក្រាបថ្វាយបង្គំ ទ្រង់ទតទៅឃើញ ត្រាស់ឲ្យបញ្ឈប់ព្រះទីនាំងហើយ យាងចុះទៅជិត ទ្រង់ទតឃើញរូបនាង ពៅ ជាកូនម៉ែស្រួសមានរូបឆោមល្អស្អាត អ្នកពាក្យកិរិយាប្រកបដោយលក្ខណៈជប្រពៃ ទ្រង់សព្វព្រះទ័យ ត្រាស់សួរថា នាងនេះជាកូនចៅនរណាឈ្មោះអ្វី ។ ម៉ែស្រួសទូលថា នាងនេះឈ្មោះនាង ពៅ ជាកូនខ្ញុំម្ចាស់ ។ ហើយស្តេចមានព្រះបន្ទូលសួរថា មានប្តីហើយឬនៅ ។ ម៉ែស្រួសទូលថា ពុំទាន់មានប្តីទេ ។ ទ្រង់ត្រាស់ថា ខ្ញុំសុំនាង ពៅ នេះយកទៅទុកគង់ព្រះបម្រើផង ម៉ែឯងថាដូចម្តេច ម៉ែស្រួសក៏ថ្វាយតាមសព្វព្រះរាជហឫទ័យ ។

ទើបទ្រង់ដឹកដៃនាង ពៅ ឡើងព្រះករថយាមួយ ឲ្យម៉ែស្រួសជិះកន្ទ្រាក់រទេះក្រឡាពាស ( ហុក ) របស់ស្តេចព្រះរាជដំណើរត្រឡប់មកព្រះរាជវាំងស្រះកែវមង្គលជ័យវិញ ។

ក្រោយនេះទ្រង់ត្រាស់បង្គាប់ឲ្យគញាក់រាំង ឲ្យទៅតខ្ញុំពរការជាព្រះរាជបំរើទៅប្រាប់ពញាជ័យជាបិតានាង ពៅ នៅភូមិក្រាំងល្វាថា ម៉ែស្រួស

ចិនឆានលីស្តេចនាំយកទៅក្នុងព្រះរាជវាំងហើយ ក៏ឲ្យពញាជ័យកិតភ័យ ស្តេចចិនលើកស្នាឲ្យតាមចាំទៀមស្រុក ព្រះរាជបំរើកទៅប្រាប់ពញាជ័យ តាមដំណើររឿងសព្វគ្រប់ ។

ថ្ងៃក្រោយ ទ្រង់ត្រាស់ឲ្យឧកញ៉ាមហាមេត្រី ចៅហ្វាយស្រុក ខែត្រក្នុងពេញឲ្យចាត់បណ្ណាការគ្រប់មុខ ដល់បានច្បាស់ល្អ ត្រាស់ប្រើ ឧកញ៉ាមហាមន្ត្រីចិនឧកញ៉ាមហាទេពជាអ្នកមហា ឲ្យជំទាវឧកញ៉ាចាំង ពីរធ្វើជាអ្នកផ្លូវ នាំបណ្ណាការទៅលើកស្នាជូនមេបានៅក្រុមក្រាំងហ្លួងប្រ ស្រេច (ទ្រង់ធ្វើនេះដើម្បីឲ្យជាប់ជាចំណែម បានជាមហាជនចាំងតួង បើ ចិនជណ្តើរកូនតែតែមានអ្នកផ្លូវអ្នកមហារៀនមកដល់សព្វថ្ងៃនេះ) ។

គមកថ្ងៃមួយ ទ្រង់តាំងអ្នកម្នាង លី ជាមហេសីធ្វើង ។ តាំងពី នោះមក ទ្រង់ត្រាស់ឲ្យធ្វើព្រះរាជប្រមាថមហាមអស់នាហ៊ានសព្វមុខមន្ត្រី ចិនបណ្តាក្រសួងតាំងតួងកុំឲ្យបរទេះគោបន្ត្រូវការកណ្តាំងចូលក្នុងបន្ទាយ កុំឲ្យជិះរទេះប្រាំងទាំងយូ ។ បើជិះទូកតែមើលឃើញកំពង់ហ្លួង ឲ្យដក កណ្តាំងខាន់ក្នុងទង់ជ័យចេញ កុំឲ្យត្រៀវគៅព្រកូនរាជ្យ កុំឲ្យសម្លាប់ គោស៊ីសាច់ ។ ទ្រង់បញ្ញត្តថា បើនាហ៊ានសព្វមុខមន្ត្រីចិនបណ្តាក្រសួង ណាមិនទទួនស្តាប់ព្រះរាជប្រមាថនេះ ឲ្យចៅហ្វាយគោហ្លួងពន្ធរទេះ១ ជាប្រាក់ ១.បាទ ។

ទ្រង់ព្រះមេត្តាប្រោសឲ្យហៅហ្វាយគោគតំបែតពន្ធគោ គិតជាពន្ធ ថ្លៃគោបាគោ ១ ជាប្រាក់ ១ បាទ ដូចមានក្នុងក្រមពុំគស្រាប់ ។

## មន្ត្រីក្បត់រត់ទៅពឹងស្តេចយួន(១)

លុះដល់ឆ្នាំថោះឯកស័ក (ព.ស. ២២៤២) ឧកញ៉ានរេន្ទ្រ (អ៊ឹម) ជាកូនខ្មោចឧកញ៉ាមហាសេនា (ម៉ិញ) ដោយទ្រង់ព្រះមេត្តាប្រោសថាជាកូនអ្នកមានត្រកូល បេះតែខ្លួនញុះញង់កាប់គិតសេនាបតីមន្ត្រីខ្លះ កើតការជាច្រើនដង ហើយពុំស្ញប់ខ្លាចព្រះបេស្តា អាងថាទ្រង់ប្រោសប្រណីណាស់ ។

ថ្ងៃក្រោយ សេនាបតីទាំងនោះបានដឹងក៏នាំគ្នាឡើងគាល់ក្រាបបង្គំទូលថាឧកញ៉ានរេន្ទ្រ (អ៊ឹម) ពុំកោតខ្លាចព្រះបេស្តា ដោយអាងថាទ្រង់ព្រះមេត្តាប្រោស ក្រោយនោះស្តេចឲ្យហៅឧកញ៉ានរេន្ទ្រ (អ៊ឹម) ឡើងគាល់ខាងក្នុង ដោយទ្រង់បង់ផ្តាំបរិយាយឧកញ៉ានរេន្ទ្រ (អ៊ឹម) តើជាពិតដូចពាក្យនាម៉ឺនសព្វមុខមន្ត្រីទាំងពួងក្រាបទូលមែនឬពុំមែនទេ ។

---

១ — Cao-Men-Ky-Luoc ហៅសករាជពី - មៅ (1699) ពេញ្ញះឧកញ៉ា- ម៉ា អា- ស៊ុ ណា - នុ - ណា - ឡុង ឯម ជាមន្ត្រីក្បត់ មកសុំទ័ពពីប្រទេសយើងទៅច្បាំងពួកដែលច្បាំងខាង ណា- យី- ទ្រី- សូ- ថា-សូ ។ កងទ័ពនេះក៏មិនមានជ័យជំនះ ហើយលើកថយទៅនៅក្បាលខ្នុះរ៉ៃទ្រូ- ទួក រួចលើកទ័ពច្បាំងម្តងទៀត តែគេចាប់បាន ណា - ឡុងឯម (នរេន្ទ្រ អ៊ឹម) បានហើយសម្លាប់បង់ទៅ ។

ប៉ុន្តែឧកញ៉ានរេន្ទ្រ (អឹម) ចូលទៅកំដរគេឃើញពុំគោរពក្រែងព្រះបេស្ដា ដូចនាហ៊ានសព្វមុខមន្ត្រីទូលថែម ហើយថែមទាំងបានទូលរឿងអ្នកផងទៀត ។

ព្រះបាទសម្ដេចព្រះបរមបពិត្រមានព្រះជន្មាសថា ខ្លួនឯងនេះ មានតែនាំរឿងអ្នកផងទៃខទូលញុះញង់ឲ្យគេកាត់ក្រហ្មាក់ឈ្មោះ ខ្លួនឯងជា កូនមហាសេនា (មិញ) ជាមនុស្សមានគុណណាស់ តែអញយល់ទៅ អាពុកឯង តាមកិរិយាឯងសមតែធ្វើទោសដាច់មួន ហើយទ្រង់ដេរ បន្ទោសប្រដៅផ្សេងៗ ។

ឯឧកញ៉ានរេន្ទ្រ (អឹម) កាលត្រូវទ្រង់ដេរបន្ទោសដូច្នោះ ក៏ខឹង ខ្ញាស់ព្រះទេពីនិងព្រះសុំពន់ពេក ដោយហេតុខ្លួនធ្លាប់ជាមនុស្សមានបក្ខមានៈ រឹងរូស ក៏គិតគុំទុំនិងព្រះបេស្ដាដែលទ្រង់មានព្រះគុណលើខ្លួន ។ លុះ ក្រោយមកព្រះវិហារចេញមកក៏គិតតែនឹងក្បត់ ដោយគិតរត់ទៅពឹងយួន ទូលញុះញង់ស្ដេចយួនឲ្យលើកទ័ពមកវាយស្រុកខ្មែរ ។ ហើយឧកញ៉ា នរេន្ទ្រ (អឹម) ពុតធ្វើជាឈឺយូរខែ រួចធ្វើសំបុត្រផ្ញើសេនាបតីឲ្យយក សេចក្ដីក្រាបបង្គំទូលថា ឈឺធ្ងន់ពុំបាន សុំថ្វាយត្រាលាលែងចេញពី ពងផងរ ក៏ទ្រង់ព្រះរាជានុញ្ញាតតាមសុំ ។

លុះថ្ងៃក្រោយមក ឧកញ៉ានរេន្ទ្រ (អឹម) បបួលគេទៅផ្ទួនឯស្រុក ក្រោមរៀងទៅរហូតដល់ស្រុកប្រទល់ដែនយួន ចូលទៅលក់ទំនិញក្នុង

ស្រុកយួន ដរាបទាល់តែបានជួបនឹងសេនាបតីយួន ហើយជំរាបពីការ
រាជការក្រុងកម្ពុជាថា ស្តេចខ្មែរពុំទ្រង់ទសពិធរាជធម៌ទេ តាំងពីបាន
សោយរាជសម្បត្តិមក បណ្តាលស្រុកទេសព្រះនគរបានសេចក្តីក្តៅក្រហាយ
ជាខ្លាំង ឥឡូវកំពុងតែគិតចាត់សេនាទាហាន ហើយជំនុំនឹងសេនាបតី
មន្ត្រីទាំងពួងថា នឹងឲ្យនាំសារទៅស្រុកសៀមយកសៀមជាកំឡាំងនឹង
លើកទ័ពមកវាយក្រុងអណ្តាមយកជាចំណុះ ដែលឲ្យមកសុំព្រះអង្គ
(អ៊ឹម) ទៅវិញនោះ ដោយបាយទឹងកាត់កំឡាំងសឹកទេ ។ កាល
កំពុងប្រឹក្សានោះខ្ញុំទូលទាស់ថា ទ្រង់ចងព្រះរាជមេត្រីនឹងគ្នាហើយត្រ-
ឡប់ជាសត្រូវវិញនេះមិនល្អទេ ស្តេចយួននឹងមើលងាយនគរយើងបាន
នោះស្តេចពុំស្តាប់ ត្រឡប់ជាទ្រង់ខ្ញាល់ឲ្យយកខ្ញុំទៅដាក់គុកហូតងារ
ខ្ញុំបានសេចក្តីអៀនខ្មាសអស់អ្នកនគរណាស់ បានជាលបរត់មកពឹងព្រះ
បរមពោធិសម្ភារព្រះចៅក្រុងអណ្តាម ធ្វើជាការថ្វាយត្រាតែអស់ជីវិត
សុំឲ្យអ្នកជួយទំនុកបំរុងខ្ញុំយកសេចក្តីក្រាបបង្គំទូលឲ្យទ្រង់ជ្រាប ហើយ
ក្រាបទូលឲ្យទ្រង់ចាត់ចងទ័ពទៅវាយក្រុងកម្ពុជាជាមុន ដែលឲ្យទៅចង
មេត្រីនឹងសៀមនោះពុំទាន់ចាត់ឲ្យទៅទេ ។ សេនាបតីក៏ទទួលពាក្យ
ថា កុំព្រួយ ខ្ញុំនឹងក្រាបទូលឲ្យទ្រង់ចាត់លើកកងទ័ពទៅជាប្រញាប់
ឲ្យបានទាន់ការ ។

ថ្ងៃក្រោយមក សេនាបតីទាំងមន្ត្រីប្អូនចូលគាល់ស្តេចយួន ក្រាបបង្គំទូលតាមពាក្យនរន្ទ្រ (អ៊ឹម) សព្វគ្រប់ ។ ស្តេចយួនទ្រង់ព្រះសណ្តាប់មានព្រះបន្ទូលថា រឿងនេះយើងមិនទាន់ជឿទេ ដ្បិតព្រះចៅក្រុងកម្ពុជានោះឮល្បីថា ប្រកបដោយទសពិធរាជធម៌ត្រឹមត្រូវណាស់ ក្រែងឧកញ៉ានរន្ទ្រ (អ៊ឹម) នេះជាមនុស្សអាក្រក់ មកញុះញង់យើងឲ្យកើតជាសង្គ្រាមនឹងគ្នាឡើង ។ នាហ្មឺនសព្វមុខមន្ត្រីដោយចង់សងសឹកខ្មែរវិញ ក៏ក្រាបទូលឡើងព្រមគ្នាថា ពាក្យនេះប្រហែលជាមែន ព្រោះឧកញ៉ានរន្ទ្រ (អ៊ឹម) នេះជាកូនឧកញ៉ាមហាសេនា (មិញ) ជាមនុស្សមានគុណបំណាច់នឹងរាជការផែនដី ឮល្បីឈ្មោះមកដល់ព្រះនគរយើង តែហេតុម្តេចបានជាឧកញ៉ានរន្ទ្រ (អ៊ឹម) ជាកូនរត់មក រឿងនេះប្រហែលជាព្រះចៅក្រុងកម្ពុជាពុំយកពាក្យឧកញ៉ានរន្ទ្រ (អ៊ឹម) មែន ។ ស្តេចយួនទ្រង់ព្រះសណ្តាប់ក៏ទ្រង់យល់ព្រមជឿតាម ទ្រង់មានព្រះបន្ទូលថា មិនគួរព្រះចៅក្រុងកម្ពុជាធ្វើយ៉ាងនេះសោះ មេត្រីនឹងគ្នាហើយបែរជាសង្គ្រាមវិញ ទើបស្តេចយួនឲ្យហៅនរន្ទ្រ (អ៊ឹម) ចូលគាល់ ទ្រង់សួរពីរាជការផែនដីគ្រប់ប្រការ ។ នរន្ទ្រ (អ៊ឹម) បានឱកាសក៏ក្រាបទូលញុះញង់គ្រប់សេចក្តី ដូចជាពាក្យសេនាបតីក្រាបទូលមកមុននោះ ។

## ព្រះរាជសង្គ្រាមគ្រាទី ៦ ច្បាំងខ្មែរនិងយួនទៀត

ទើបស្តេចយួនត្រាស់បង្គាប់មន្ត្រីខ្ញុំរាជការ ឲ្យកេណ្ឌពលសេនាទាហានឲ្យបានចំនួន ៤០.០០០ ទូក ៥០០ និងគ្រឿងសស្ត្រាវុធគ្រប់ប្រដាប់សព្វគ្រប់ ។

ដល់ខែអស្សុជឆ្នាំថោះឯកស័ក (ព.ស. ២២៤២) ស្តេចយួនត្រាស់ប្រើអុងវៀងតុន ១ អុងបាហោ ១ ឲ្យនាំពលយួនចុះទូកលើកមកកាយប្រទេសកម្ពុជា ។ កញ្ញានរេន្ទ្រ (រ៉ាម) ជាអ្នកនាំផ្លូវ អុងយួនទាំងពីរនាំសេនាទាហានលើកពលចុះទូកឡើងតាមទឹកមក ដល់ប្រទល់ដែនកម្ពុជាក៏ចែកទ័ពជាពីរកង អុងវៀងតុនលើកទ័ពពល ២០.០០០ កាយតាមទន្លេមាត់ជ្រូកឡើងវៀងមក អុងបាហោកាត់តាមទន្លេល្វាឯមឡើងវៀងមក ។

ចៅហ្វាយស្រុកខ្មែរគ្រប់ខេត្តក៏បាននាំកេណ្ឌពលសេនា ទទួលច្បាំងតទល់នឹងកងទ័ពយួនតែពុំឈ្នះ ក៏នាំប្រពន្ធកូនចៅក្រុមការដោះខ្លួនរត់ចូលព្រៃ រួចធ្វើសំបុត្របង្គំទូលមកសេនាបតី ឲ្យយកសេចក្តីក្រាបបង្គំទូលតាមហេតុដែលយួនលើកទ័ពមកពីផ្លូវ ។ កញ្ញានរេន្ទ្រ (អ៊ំម) ជាអ្នកនាំផ្លូវមកផង ចៅហ្វាយស្រុកគ្រប់ខេត្តតាមមាត់ទន្លេ លើកទ័ពច្បាំងតទល់នឹងយួនពុំឈ្នះយួន ឥឡូវលើកទ័ពកាយកុកពនឡើងវៀងមក ហើយ សេនាបតីក៏យកសេចក្តីក្រាបបង្គំទូលឲ្យទ្រង់ជ្រាបគ្រប់ប្រការ ។

លុះទ្រង់ជ្រាប ស្តេចប្រឹក្សានឹងសេនាបតីមន្ត្រីទាំងពួងថា មិនគួរស្តេចយួនកាត់ផ្លូវព្រះរាជមេត្រីសោះ រឿងនេះប្រាកដជាកើតពីអានេន្ទ្រ (អឹម) ជាមនុស្សអកតញ្ញូញុះញង់ អោយគេទាំងពួងយល់ដូចម្តេច ៗ នាហ៊ឺនសព្វមុខមន្ត្រីក៏ក្រាបបង្គំទូលថា នេះពីព្រោះតែយើងធ្វេសប្រហែសអោយទុកចិត្តថាមេត្រីនឹងគ្នាហើយ ឥឡូវយួនលើកទ័ពមកវាយស្រុកយើងមុន ត្រូវយើងកេណ្ឌកងទ័ពទៅទូលច្បាំងកណ្តាលផ្លូវកុំឲ្យយួនលើកមកទៀតបាន ៗ កាលកំពុងតែប្រឹក្សាគ្នា មានបុកហ្វាយទៅហ្វាយស្រុកក្រាបទូលមកទៀតថា យួនលើកទ័ពចូលគ្រោះណាស់ វាយបានខែត្រមាត់ទន្លេអស់ហើយ បោះទ័ពនៅព្រែកភ្នាត ១ អន្លើ នៅព្រែកឈ្លាងម ១ អន្លើបណ្តាមហាជននាំគ្នារត់ចោលផ្ទះសម្បែងភូមិលំនៅទៅអស់ ទៅពួននៅក្នុងព្រៃ ទ័ពយួនដុតផ្ទះសម្បែងបណ្តារាស្ត្រយកទ្រព្យសម្បត្តិទៅជាច្រើន ទ្រង់ជ្រាបទ្រង់ព្រួយព្រះទ័យក្រៃពេក ៗ

ហើយទ្រង់ប្រឹក្សានឹងសេនាបតីទាំងពួងថា ទ័ពយួនលើកមកជិតណាស់ហើយ តើអ្នកទាំងពួងយល់ដូចម្តេច ៗ នាហ៊ឺនសព្វមុខមន្ត្រីក្រាបបង្គំទូលថា ផ្លូវនេះមានផ្លូវទឹកលិចដល់ទាំងផ្លូវទឹកផ្លូវគោក ទ័ពយួនលើកមកធ្វើបន្ទាយក៏ជិតក្រុង ទូលបង្គំទាំងអស់គ្នាយល់ថា សូមឲ្យស្តេចនាំព្រះរាជវង្សានុវង្ស ព្រះមហេសីព្រះរាជទេវី ព្រះស្នំមន្ត្រីរាជការ ព្រះរាជដំណើរទៅប្រថាប់នៅខែត្រពោធិ៍សាត់សិន ងាន

កាជសព្រៃនោះទូលព្រះបង្គំជាខ្ញុំទីងគិតធ្វើការយកជ័យជំនះឲ្យបាន សូមកុំព្រួយព្រះទ័យ ទ្រង់ព្រះសណ្ដាប់ក៏ទ្រង់យល់ព្រម ។

ទ្រង់ត្រាស់បង្គាប់មន្ត្រីខ្ញុំរាជការឲ្យរៀបព្រះទីនាំងនាវា ព្រះទីនាំងគជេន្ទ្រ ជញ្ជូនព្រះរាជទ្រព្យផ្ទុកស្រេច ស្ដេចត្រាស់បង្គាប់ខ្ញុំរាជការឲ្យបាត់សេនាទាហានដែលមានចំនួន ៤.០០០ នៅចាំព្រះបរមរាជវាំងគិរីគុត្តពុទ្ធជ័យ ត្រាស់បង្គាប់សេនាបតីឲ្យធ្វើសំបុត្រប្រាប់ទៅចៅហ្វាយស្រុកគប់ខែត្រ ឲ្យកេណ្ឌពលបញ្ចូលជាកងទ័ព ឲ្យធ្វើបន្ទាយការពារទីជាប់យាមល្បាតរក្សាខែត្រ គប់ផ្លូវច្រើនអន្លើឲ្យមាំមួន កុំឲ្យយួនឡើងពីទន្លេបាន ។ បំណែកគ្រួខ្ទះគោកប្រមូលឲ្យទៅនៅស្រុកលើឲ្យអស់ ។

ថ្ងៃ ៨ កើតខែអស្សុជ ឆ្នាំថោះឯកស័ក (ព. ស. ២២៤២) ស្ដេចនាំព្រះមហេសីព្រះស្នំព្រះរាជវង្សានុវង្ស ខ្ញុំរាជការស្ដេចឡើងគង់ព្រះទីនាំងគជេន្ទ្រ មន្ត្រីខ្ញុំរាជការខ្លះជិះទូកជិះដំរី ព្រះរាជដំណើរចេញពីព្រះបរម-រាជវាំងគិរីគុត្តពុទ្ធជ័យ ៨ ថ្ងៃដល់ខែត្រពោធិសាត់ ត្រាស់ឲ្យធ្វើដំណាក់បន្ទាយព័ទ្ធ-គូបគង់នៅទីនោះ ។

ថ្ងៃក្រោយ ស្ដេចត្រាស់បង្គាប់មន្ត្រីខ្ញុំរាជការឲ្យចេញទៅកេណ្ឌរាស្ត្រក្នុងខែត្រពោធិសាត់ បាត់ដំបង មហានគរ (សៀមរាប) កំពង់ស្វាយបានចំនួន ៤០.០០០ មកប្រជុំនៅខែត្រពោធិសាត់រក្សាព្រះអង្គ ។

(មានត)

# ប្រយោជន៍របស់ធម្មៈ ក្នុងពុទ្ធសាសនា

ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ រៀបរៀង

(តមកនិងចប់)

---

សត្ថុបាវចនៈ (ពាក្យជាប្រធានរបស់ព្រះសាស្តា) មាន ២ យ៉ាងគឺធម៌ ១ វិន័យ ១ ។ ពាក្យថាធម៌ជាពិធីសម្រាប់ត្រួតត្រាការពារកិលេសខាងផ្លូវចិត្ត, ពាក្យថាវិន័យជាច្បាប់ត្រួតត្រាការពារកិលេសខាងផ្លូវកាយនិងវាចា, មួយទៀត ក្នុងអដ្ឋកថាសង្គីតិសូត្រចែកសត្ថុបាវចនៈ នេះជា ៤ យ៉ាងគឺធម៌ ១ អភិធម៌ ១ វិន័យ ១ អភិវិន័យ ១ ។ ពាក្យថាធម៌បានដល់ពុទ្ធវចនខាងគម្ពីរព្រះសូត្រ, អភិធម៌ បានដល់ពុទ្ធវចនខាងបរមត្ថ; វិន័យ បានដល់កគោវិកដ្ឋដែលនិយាយអំពីការចែកសិក្ខាបទចេញជាពីរពួកគឺសិក្ខាបទភិក្ខុនិងភិក្ខុនី, អភិវិន័យ បានដល់ពុទ្ធានុញ្ញាតនិងពុទ្ធប្បញ្ញត្តិក្នុងខន្ធកៈនិងបរិវារៈ ។ ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធសំដែងទុកមកដើម្បីប្រយោជន៍ដ៏ធំបំផុតនោះ ក៏គឺសម្រាប់ទូន្មានបង្ក្រាបសឹកសត្រូវគឺកិលេសជាខាងកណ្តាលនិងល្អិតដែលកើតអំពីផ្លូវចិត្ត, វិន័យដែលព្រះអង្គបញ្ញត្តទុកមកមានប្រយោជន៍វិសេសក្នុងការតទល់នឹងសឹកសត្រូវគឺកិលេសគ្រោតគ្រាតដែលកើតអំពីកាយវាចាប៉ុណ្ណោះឯង ឬថាធម៌វិន័យនេះទុកដូចជាថ្នាំបន្សាបនូវពិសកាចគឺកិលេសរបស់ប្រជាជនក្នុងលោក ឲ្យសាបរលាប ឲ្យស្ងប់រម្ងាប់ដូច្នេះក៏បាន ។

បណ្ដាប្រទេសទាំងអស់ក្នុងលោកនេះ ប្រទេសមួយៗតែងមានទោសកំណាចជាធម្មតា, អ្នកប្រទេសនោះក៏ត្រូវតាំងបញ្ញត្តច្បាប់ឲ្យមានឥស្សរជនខាងស្ដេចជាដើមឲ្យជាអ្នកគ្រប់គ្រងអ្នកប្រទេសឲ្យបានសុខចំរើន ការពារមនុស្សទុច្ចរិតទាំងនោះកុំឲ្យកក្រាកសង្កត់សង្កិនមនុស្សអ្នកប្រទេស សេចក្ដីនេះយ៉ាងណាមិញ សរីរប្រទេសគឺកាយទាំងមូលរបស់យើង ក៏តែងមានពួកទោសកំណាចគឺកិលេសឬបាបធម៌ដូចគ្នា . យើងដែលមានកុសលក្នុងសន្ដានត្រូវបញ្ញត្តច្បាប់រៀបចំ តាំងបញ្ញាការបេះដូងឲ្យជាអធិបតីសម្រាប់គ្រប់គ្រងការពារឧបក្កិលេសដែលជាសត្រូវទាំងនោះកុំឲ្យរុករានទន្ទ្រាន ចូលក្នុងកាយប្រទេសបានក៏យ៉ាងនោះដែរ ។ ។ ឥស្សរជនគឺអ្នកធំដែលជានាយកគ្រប់គ្រងប្រទេស ត្រូវតែតាំងច្បាប់អាជ្ញាក្លាហានមិនត្រូវខ្លាចសត្រូវគឺទោសកំណាចទុច្ចរិត ត្រូវតែយកជ័យជំនះមិនត្រូវបណ្ដោយឲ្យចាញ់ទោសកំណាចយ៉ាងណា, យើងជាពុទ្ធិកជនត្រូវយកញាណជាស្មារតីឲ្យជានាយកគ្រប់គ្រងប្រទេសគឺកាយ ហើយត្រូវកាន់ក្រិត្យក្រមច្បាប់អាជ្ញាគឺធម៌វិន័យកុំភ្លេចខ្លួន ដើម្បីផ្ចាញ់សត្រូវគឺឧបក្កិលេសសេចក្ដីសៅហ្មងឲ្យចាលចាញ់ក៏យ៉ាងនោះដែរ ។

ប្រយោជន៍របស់ធម្មៈក្នុងព្រះពុទ្ធសាសនាដែលប្រសើរបំផុតនោះ ក៏គឺប្រមូលសន្សំសេចក្ដីប្រតិបត្តិល្អ ទុកជាទឹកកំឡាំងសម្រាប់ប្រយុទ្ធយក

ជ័យជំនះឲ្យឈ្នះកិលេសសេចក្តីកក្រក់ក្នុងខ្លួន ទើបរាប់ថាជាការឈ្នះដ៏ប្រសើរដែលជាហេតុឲ្យកើតសន្តិសុខ សមដូចពុទ្ធភាសិតថា

អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា
បជា ប៉ុណ្ណោះជាដើម ។

សេចក្តីថា "ការឈ្នះខ្លួនឯង ជាការប្រសើរជាង (ឈ្នះគេ) ពពួកសត្វដែលឈ្នះក្រៅពីនេះ (ពុំប្រសើរឡើយ)" ។ ពុទ្ធភាសិតនេះបំភ្លឺសេចក្តីថា ការឈ្នះកិលេសដែលជាបច្ចាមិត្តក្នុងខ្លួន ទើបរាប់ថាឈ្នះពិតមិនត្រឡប់ចាញ់វិញ ទោះបីទេវតា គន្ធព្វ មារ ព្រហ្ម ក៏មិនអាចនឹងដណ្តើមយកជ័យជំនះវិញបាន ។ ពាក្យថា ឈ្នះក្នុងទីនេះសំដៅយកចិត្តដែលមិនលុះក្នុងអំណាច មិនក័ន្តកាំងទៅតាមអារម្មណ៍ជាទីតាំងនៃកិលេស ការឈ្នះដូច្នេះឈ្មោះថាជាការឈ្នះរបស់[illegible] ។

ការឈ្នះទាំងអស់ក្នុងលោក ក៏រមែងមានចាញ់នឹងឈ្នះជាធម្មតា ដូចការលេងល្បែងផ្សេងៗ មានបគ្គ ឬ បៀ ជាដើម រហូតដល់ការប្រកាសសង្គ្រាមច្បាំងគ្នាដល់ប្រទេសតែមានការចាញ់ឈ្នះទៅវិញទៅមក, ជួនកាលពួកម្ខាងឈ្នះ ជួនកាលពួកដែលធ្លាប់ឈ្នះក៏ត្រឡប់ជាចាញ់វិញ, ការចាញ់និងឈ្នះទាំងនេះស្រេចនឹងឧបាយកល ឬ កំឡាំងរេហ៍ពល, អ្នកដែលចាញ់ក៏មិនចាញ់រហូត អ្នកដែលឈ្នះគេក៏មិនឈ្នះរហូត, អ្នកដែលចាញ់ក៏ជាទុក្ខក្រៀមក្រំដកសក្តិក្ស័យ, អ្នកដែលឈ្នះក៏ឈ្មោះថាប្រមូលសេចក្តីទុក្ខភ័យពៀរវេរាថែមទៀត ។

ការចាញ់ឈ្នះនេះឃើញថាមិនមានទីបំផុតឡើយ សុទ្ធតែជាមូលហេតុនៃសេចក្តីវិនាសទុក្ខព្រួយទាំងអស់ ដូចយ៉ាងសង្គ្រាមរបស់ព្រះបាទបសេនទិកោសលនឹងព្រះបាទអជាតសត្តុ ជាឧទាហរណ៍ កាលលើកដំបូងនិងលើកទី ២ ព្រះបាទអជាតសត្តុមានជ័យជំនះ, បំណាក់ខាងព្រះបាទបសេនទិកោសល ក៏ជាទុក្ខក្រៀមក្រំក្នុងព្រះហឫទ័យស្ទើរជាប់ជន្មាយុ ហើយក៏បង្កាយាតគុំគួន ចាំនឹងដណ្តើមយកជ័យវិញឲ្យបាន, លុះចាំជាលំដាប់តមក ព្រះបាទបសេនទិកោសល ក៏ប្រឹងប្រែងប្រមូលរៀបចំយុទ្ធោបករណ៍ និងរកពលទាហានលើកទៅច្បាំងសង្គ្រាមតទល់នឹងព្រះបាទអជាតសត្តុម្តងទៀត ជាសង្គ្រាមលើកទី ៣ ។ វេលានោះព្រះបាទអជាតសត្តុក៏ត្រឡប់ជាបានយុទ្ធបរាជ័យ ចាលចាញ់តេជះព្រះបាទបសេនទិកោសលវិញ ដូចយ៉ាងសង្គ្រាមក្នុងលោកនេះក៏រមែងចាញ់ឈ្នះគ្នាទៅវិញទៅមក ជាប្រែងលើកប្រែងគ្រាជាធម្មតា, ការចាញ់ឈ្នះដោយល្បែងផ្សេងៗឬដោយការប្រកាន់ ទាំងអស់នេះជារបស់នៅប្រែប្រួលមិនមែនជាសារៈមាំមួន ប្រសើរទៀងទាត់ឡើយ ដំណើរនេះសមដូចពុទ្ធភាសិតថា :

ន តំ ជិតំ សាធុ ជិតំ យំ ជិតំ អវជីយតិ

តំ ខោ ជិតំ សាធុ ជិតំ យំ ជិតំ នាវជីយតិ ។

សេចក្ដីថា៖ អំពើឯណាដែលគេឈ្នះហើយ ត្រឡប់ចាញ់វិញ អំពើ
នោះមិនកប់ថាល្អប្រពៃឡើយ លុះតែអំពើឯណាដែលគេឈ្នះហើយ មិន
ត្រឡប់ចាញ់វិញទេ អំពើនោះទើបឈ្មោះថាប្រពៃដោយពិត ។ ពុទ្ធ-
ភាសិតដែលគាប់មកនេះគួរយើងឃើញច្បាស់ថា ការឈ្នះក្នុងលោកនេះជា
ការមិនប្រសើរដូចការឈ្នះកិលេសក្នុងខ្លួនឯងនោះឡើយ ។ ការឈ្នះ
កិលេសក្នុងទីនេះ សំដៅយកសមុច្ឆេទប្បហាន គឺការលះកិលេសឲ្យ
ដាច់ស្រឡះ, ចំណែកខាងយើងជាពុថុជ្ជនគ្រាន់តែឈ្នះដោយតទង្គប្ប-
ហានទិនវិក្ខម្ភនប្បហានប៉ុណ្ណោះទេ យើងត្រូវទូន្មានខ្លួនឲ្យមានបុគ្គលា
សណ្ដាប់ធ្នាប់ល្អ គ្រាន់តែមិនឲ្យស្រើងច្រើលជ្រប់តាលទាញទៅកិលេស
ដ៏គ្រោតគ្រាតហើយទើបបានដាក់ខ្លួនទុកក្នុងធម៌ដ៏សមគួរ គឺកុសល
សម្មាបដិបត្តិជាគ្រឿងប្រុង តាមនាទីរបស់យើងដែលគួរជ្រើសយកតែ
ប៉ុណ្ណោះក៏ជាការប្រពៃណាស់ហើយ ។

កិលេសបុប្ផាបធម៌ ដែលជាសត្រូវដូចបានកប់ឈ្មោះទុកមក
ខាងដើម កាលបើខ្លួនយើងបានឈ្នះហើយក៏ត្រូវរក្សាជ័យជំនះនោះទុក
ដោយល្អ ឲ្យដូចជាគំបិលដែលគេរក្សាជាតិប្របស់ពុទ្ធម៉ូហ្នះដែរ មួយ
ទៀតការរក្សាជ័យជំនះមិនឲ្យកិលេសបុប្ផាបធម៌ កើតកើតឡើងបាននោះ
ត្រូវដឹកល់ខ្លួនទុកក្នុងព្រះសទ្ធម្ម ៧ ប្រការដូចមហាក្សត្រគ្រប់គ្រងនគរ ។
បុគ្គលឯណាដែលប្រាសចាកព្រះសទ្ធម្ម បុគ្គលនោះឈ្មោះថាជាអ្នកព្រម

ទាញកិលេសមារនៅក្នុងការបណ្ដាប់នៃកិលេសមារជាអន្លង់តទៅមិនមានទីបំផុត ។ សេចក្ដីនេះ សម្ដែងពុទ្ធដីកាក្នុងគម្ពីរអង្គុត្តរនិកាយសត្ត-កនិបាតថា មហាក្សត្រម្ចាស់ផែនដី តែងការពារនគរដោយគ្រឿងបរិក្ខារ ៧ យ៉ាង:

ទី ១ ឯសិកា បោះសសរគោលយ៉ាងជ្រៅ ៗ ដែលធ្វើអំពីថ្ម ឬឈើមិនឲ្យគេរើចេញកើតបាន

ទី ២ បរិក្ខាភោ ជីកចន្ទ្រូងឬស្នាមភ្លោះយ៉ាងជ្រៅធំព័ទ្ធខាត់ខ្វែង ត្រង់ព្រំប្រទល់ដែនរបស់ខ្លួន

ទី ៣ អនុបរិយាយបថោ ធ្វើផ្លូវសម្រាប់យាមល្បាតតាំងខាង ក្នុងកំពែងក្រៅកំពែងមិនឲ្យបច្ចាមិត្តចូលបាន

ទី ៤ ពហុ អាវុធំ សន្សំគ្រឿងអាវុធទុកឲ្យបានច្រើន

ទី ៥ ពហុពលកាយោ កេណ្ឌពួកពលទាហានបង្ហាត់បង្រៀនទុកឲ្យបានច្រើនសម្រាប់ចាត់ការមិនឲ្យខ្វះពល

ទី ៦ ទោវារិកោ មានទាហានចាំទ្វារនគរផ្លាស់ប្ដូរជានិច្ច

ទី ៧ បាការោ មានកំពែងព័ទ្ធជុំវិញនគរជាច្រើនជាន់ ៗ

នគរឯណាដែលបានការពារប្រយ័ត្នដោយនគរបរិក្ខារ ៧ យ៉ាងនេះ នគរនោះរមែងមានសេចក្ដីកក់ក្ដៅ ឥតកើតខូចខាតពីសត្រូវដែលមកបៀតបៀន សេចក្ដីនេះយ៉ាងណាមិញ អរិយសាវ័កក្នុងពុទ្ធសាសនានេះ

ដែលប្រកបដោយព្រះសទ្ធម្ម ៧ ប្រការ ជាគ្រឿងការពារខ្លួន ក៏រមែងបានសេចក្ដីសុខសប្បាយ ឈ្នះមារសត្រូវមិននៅក្នុងចំណុះនៃកិលេសមារ គឺយ៉ាងនោះដែរ ។

អរិយសាវកដែលប្រកបដោយព្រះសទ្ធម្ម ៧ ប្រការនោះ គឺ

ទី ១ សទ្ធា ជឿកម្មនិងផលរបស់កម្មនិងជឿគុណព្រះរតនត្រ័យ

ទី ២ ហិរិមា មានចិត្តអៀនខ្មាសមិនហ៊ានលួចប្រព្រឹត្តទុច្ចរិត

ទី ៣ ឱត្តប្បី មានចិត្តខ្លាចរអាចំពោះអំពើទុច្ចរិត

ទី ៤ ពហុស្សុតោ ជាអ្នកបានសិក្សារៀនសូត្រចេះដឹងច្រើន

ទី ៥ អារទ្ធវិរិយោ មានព្យាយាមមិនដាច់ មិនដាក់ធុរៈក្នុងកុសលធម៌

ទី ៦ សតិមា មានស្មារតីល្អចាំដាក់ក្នុងការរក្សាខ្លួនមិនឲ្យភាន់ក្នុងអារម្មណ៍ដែលជាអាហារចំណីនៃកិលេសមារ

ទី ៧ បញ្ញវា មានប្រាជ្ញាជាអាវុធជម្នះសម្រាប់កំចាត់និងកិលេសមារ ដោយការពិចារណាឃើញច្បាស់នូវកើតនិងរលត់នៃសង្ខារ ។

បើបុគ្គលណាមួយបានដក់ល់ខ្លួននៅក្នុងព្រះសទ្ធម្ម ៧ ប្រការ ដូចពោលមកនេះ បុគ្គលនោះនឹងបានសេចក្ដីសុខក្សេមក្សាន្ត ចៀសឆ្ងាយទុក្ខភ័យឥតមានសត្រូវ គឺកិលេសមារមកសង្កត់ ឬមកយាយីដណ្ដើមបែកយុទ្ធជ័យបានវិញឡើយ បុគ្គលនោះនឹងត្រូវឈ្នះរាបតទៅ រហូតបានមគ្គផលព្រះនិព្វានជាទីបំផុតលោកដោយពិត ។

ផលប្រយោជន៍របស់ធម៌ៈ ក្នុងព្រះពុទ្ធសាសនានេះ, រមែងឃើញទាន់ក្នុងក្នុងសម័យបច្ចុប្បន្ន បើយើងប្រព្រឹត្តកាន់តាមដោយទៀងទាត់ ។ ព្រោះថា ពុទ្ធសាសនា មានវិធីប្រដៅប្រដាំជនឲ្យស្គាល់មូលហេតុដើមកំណើតនៃសេចក្ដីសុខ-ទុក្ខ ដូចប្រដៅថា ក្លេសៈកិលេសគឺៈ លោភៈ ទោសៈ មោហៈ មានៈ ប៉ុណ្ណោះជាដើម ទាំងនេះជាទ្វារសម្រាប់ចូលមកនៃសេចក្ដីទុក្ខ ឬថាជាជននាំបង្កឲ្យកើតទុក្ខ ។ ពួកសត្វលោកកាលបើព្រមបើកអំណាចឲ្យកិលេសទាំងនោះចូលមកគ្របសង្កត់ ឬបណ្ដោយឲ្យកិលេសមានកំឡាំងមានសំទុះខ្លាំងឡើងហើយ កិលេសទាំងនោះមុខជានឹងស្រែកហៅសេចក្ដីវិនាស ដែលជាមេនៃសេចក្ដីទុក្ខដ៏ក្រៃលែង ។ លុះតែយើងឈ្នះកិលេសទាំងនោះបាន ទើបសេចក្ដីសុខសេចក្ដីចំរើននឹងលេចច្បាស់ប្រាកដឡើងក្នុងបច្ចុប្បន្ននេះឥតអាក់ឡើយ ។

ដើម្បីធ្វើកាយវាចាចិត្តឲ្យស្លូតត្រង់ ព្រះពុទ្ធសាសនាប្រដៅប្រដាំជនក្នុងលោកមិនឲ្យប្រើអំណាចបៀតបៀនគ្នាដោយដាច់ខាត ។ ព្រះពុទ្ធសាសនាជាជំនួយដល់ផ្លូវលោក គឺថាជាច្បាប់សម្រាប់ទប់សត្វលោកមិនឲ្យប៉ះទង្គិចគ្នា ដូចចង្កូតនិងគ្រឿងទប់រថយន្ត ដែលជាប្រយោជន៍ក្នុងគ្រឿងយន្ត មិនឲ្យបុកគ្នាបាន ឬ មិនឲ្យជ្រុលជ្រួសក្លូកក្រឡាប់ទៅបាន ។ សត្វលោកកាលបើប្រើតែច្បាប់ផ្លូវលោកមួយមុខ ក៏ទុកដូចជារថយន្តដាច់ចង្កូត ឬ គ្មានគ្រឿងទប់ ព្រោះផ្លូវធម៌ទុកដូចជាចង្កូតនិង

គ្រឿងទប់ទល់ទុក្ខ ។ មួយទៀត ពុទ្ធសាសនា ដូចទឹកសម្រាប់លត់ភ្លើងទុក្ខភ្លើងកិលេសរបស់សត្វលោក ឬជាជាតូកំឡាំងសម្រាប់ជួយផ្ទុះវាលក ជួយសម្រាលទុក្ខភ័យការៈដ៏ធ្ងន់ក្នុងផ្លូវលោកដូចនេះក៏បាន ។

សត្វលោកទាំងអស់បើស្រុះស្រួលព្រមព្រៀងគ្នាប្រតិបត្តិជឿកាន់តាមផ្លូវធម៌ដោយខ្ជាប់ខ្ជួនមែននោះ ប្រាកដជាបានសេចក្ដីសុខចំរើនដោយពិត សូម្បីទ្វារផ្ទះក៏មិនបាច់បើកទុះសម្រាប់ទាស់ មិនបាច់ចាក់សោការពារចោរឡើយ ។ ផ្លូវធម៌ប្រើសោហ៊ុយបន្តិចបន្តួច មិនចុះសោហ៊ុយច្រើនដូចគ្រឿងបរិក្ខារខាងផ្លូវលោកទេ តែសេចក្ដីសុខរបស់អ្នកកាន់ផ្លូវធម៌គឺគង់សម្បូណ៌ជាលំដាប់ តាំងអំពីបច្ចុប្បន្ននេះរហូតដល់ព្រះនិព្វានជាទីបំផុត ។

ប្រយោជន៍ដ៏ខ្ពស់បំផុតរបស់ធម្មៈក្នុងពុទ្ធសាសនា នោះគឺការឈ្នះកិលេសធ្វើខ្លួនឲ្យបានដល់ព្រះអរហត្តនិព្វាន ទើបរាប់ថាជាជំនះឈ្នះប្រយោជន៍ដ៏ប្រសើរ ជាហេតុឲ្យរួចចាកទុក្ខទាំងលោកនិងបរលោកទាំងពីរពិត ព្រោះបើកិលេសបាបធម៌ទាំងឡាយមានលោភគ្នាដើម ត្រូវបានផ្ដាច់ចេញទៀតហើយ ឬជាជាដើមពូជនៃសេចក្ដីទុក្ខត្រូវបានដុតបំផ្លាញចោល ឈ្នះកិលេសអស់ហើយដូចបាលា ឈ្មោះថាផុតក្ដៅពីសេចក្ដីទុក្ខភ័យក្នុងអនាគតជាតិខាងមុខនោះដែរ នេះឯងឈ្មោះថាប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ធម្មៈក្នុងពុទ្ធសាសនា ដូចពណ៌នាមកប៉ុណ្ណេះ ។ ប៉ុម ឌិត ហោ (ចប់ ...

---

ប្រវត្តិ

# ព្រះធម្មចរិយាព្រឹទ្ធបិដ្ឋាសេដ្ឋាភជាគណៈ កែវ ជួន

## ចៅអធិការវត្តកំសំពៅមេគណខេត្តបាត់ដំបង

---

លោកគ្រូមេគណ កែវ-ជួន វត្តកំសំពៅ ខេត្តបាត់ដំបង ប្រសូតក្នុងឆ្នាំកុរ ពុទ្ធសករាជ ២៤១៧ (គ. ស. ១៨៧៤) ស្រុកកំណើតរបស់លោកនៅភូមិចន្ទាយដែក ឃុំត្រាង ខេត្តទ្រាំងត្រើយខាងត្បូង ។

កាលលោកនៅជាកុមារបានសិក្សាអក្សរសាស្ត្រ ក្នុងសំណាក់គ្រូ បានរះចាំមើលអក្សរជាប់សរសេរកើតសព្វគ្រប់ ។

លុះដល់អាយុ ២០ ឆ្នាំ លោកបួសបួសជាភិក្ខុ ក្នុងពទ្ធសីមាវត្តព្រៃមលង ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ លោកគ្រូព្រះបទុមវង្សា ទា (ធម្មជោតោ) វត្តព្រៃមលង ជាព្រះឧបជ្ឈាយ៍លោក គ្រូព្រះគ្រូកែនបាមោក្ខវិសុទ្ធវង្សា បា (សុវណ្ណជោតោ) ជាកម្មវាចាចារ្យ-អនុសាវនាចារ្យ (គ្រូសូត្រ) ។ លុះបួសរួចហើយលោកចេញពីវត្តទៅរៀនព្រះបរិយត្តិធម៌បាលីបច់ត្រឹមមូលកច្ចាយនៈក៏ឈប់រៀនទៅ ។

តពីនោះមក លោករៀនខាងសមថភាវនាហើយកាន់ធុតង្គវត្តប្រែន ដើរនៅតែក្នុងព្រៃ បានចូលទៅនៅក្នុងខេត្តបាត់ដំបង (កាលនោះនៅក្នុងរាជការសៀម) លោកបានចូលទៅធ្វើសមថភាវនាលើភ្នំសំពៅជាយូរ ឆ្នាំ

អង្វែងឆ្នាំ ពេលនោះអ្នកស្រុកនៅជិតភ្នំសំពៅមានសេចក្តីជ្រះថ្លានឹងលោកជាច្រើន បានចូលទៅធ្វើជាកូនសិស្សរៀនសមថភាវនាក្នុងសំណាក់លោកពុំរើសនាក់ លោកក៏ខំយកចិត្តទុកដាក់បង្ហាត់បង្រៀនសមថ-ភាវនាដល់ពួកអ្នកស្រុកទាំងនោះព្រមទាំងបព្វជិតនឹងគ្រហស្ថក្នុងមួយឆ្នាំៗ មានចំនួនប្រហែល ៦-៧ រយរូប ដល់មកឆ្នាំកេន គ.ស. ១៩០៤ ពួកអ្នកស្រុកទាំងនោះ បានសាងវត្ត ១ នៅជិតភ្នំសំពៅនោះប្រគេនលោក ឲ្យឈ្មោះថាវត្តភ្នំសំពៅ ហើយនិមន្តលោកឲ្យធ្វើជាចៅអធិការនៅវត្តនោះដរាបមក ។

លុះដល់មកឆ្នាំមមែ គ.ស. ១៩០៧ ស្រុកបាត់ដំបងត្រឡប់បានមកខ្មែរវិញ បណ្តារាស្ត្រខ្មែរក្នុងស្រុកបាត់ដំបងច្រើនស៊ីត្រូវចិត្តនឹងពួកសៀម មិនសូវស៊ីត្រូវចិត្តនឹងពួកការខ្មែរ ពួកខ្លះក៏ភ័យព្រួយគិតនាំគ្នារត់ទៅនៅស្រុកសៀម ពួកខ្លះចំនួនជាងពាន់នាក់ បាននាំគ្នារត់ទៅពួនសម្ងំនៅក្នុងព្រៃ តពួនជាទ័ពប្រឆាំងនឹងរាជការខ្មែរ-បារាំង ទ័ពដែលបះបោរនៅក្នុងព្រៃនោះ មានមនុស្សម្នាក់ឈ្មោះញ៉ូវ ជាមេគេទាំងអស់ តាមអ្នកស្រុកគេហៅថាទ័ពលោកវិសេសញ៉ូវ ដោយហេតុមានចលាចលយ៉ាងនេះ ទើបរាជការខ្មែរ-បារាំង បានឲ្យលោកគ្រូកែវ-ជួនចៅអធិការវត្តភ្នំសំពៅទៅនិយាយបញ្ចុះបញ្ចូលពួកបណ្តារាស្ត្រឲ្យរត់ទៅនៅស្រុកសៀម

កុំឲ្យនាំគ្នាកើតពួកផ្ដាច់ពាក់នៅក្នុងព្រៃជ្រោះទៀត ត្រូវនាំគ្នាត្រឡប់ចូលមកនៅក្នុងស្រុកវិញនៅឲ្យស្ងប់ស្ងៀម ។

តាមដែលបានឮមកថា លោកគ្រូចៅអធិការវត្តកំសំពៅ បានចូលទៅនិយាយតណ្ដាលចំណោមចំពក វិសេសញ៉ែដែលកំពុងកាន់គ្រឿងអាវុធប្រុងប្រៀងនៅដៃ កាលលោកនិមន្តទៅដល់ភ្លាមពួកចំពវិសេសញ៉ែដម្រង់គ្រឿងអាវុធចំពោះលោកប្រុងនឹងបាញ់ តែលោកមានថេរដីកាទៅកេពួកចំពទាំងនោះថា "កុំអាលសម្លាប់អាត្មាចាំឲ្យអាត្មានិយាយសិន" ហើយលោកក៏មានថេរដីកាសម្រុះសម្រួលដោយគល់ៗពាក្យផ្សេងៗ អស់វេលាជាង ៣ ម៉ោង លុះលោកមានថេរដីកាចប់សព្វគ្រប់ហើយ ទើបពួកចំពវិសេសញ៉ែទាំងនោះដាក់គ្រឿងអាវុធចុះគ្រប់គ្នា ត្រឡប់មកនៅស្រុកវិញ ។ ចាប់ដើមពីនោះមកពួករាស្ត្រនៅខែត្របាត់ដំបងទាំងអស់ក៏លែងផ្អើលភ្ញាក់ នាំគ្នាមកនៅក្នុងស្រុករកស៊ីបរិភោគជាវិតថ្កាយស្ងប់ស្ងៀមតាមធម្មតា លែងមានរបះរបោរកោលាហលពីគ្រានោះឯង ។ ចាប់ពីនោះមក លោកគ្រូចៅអធិការវត្តកំសំពៅ បានចូលមកគាល់សម្ដេចព្រះមហាសង្ឃរាជព្រះនាម ទៀង ឯដំណាក់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ លោកបានអធិប្បាយអស់គរុដ្ឋានថ្វាយ សម្ដេចទ្រង់ព្រះសណ្ដាប់អស់វេលាពេញ ១ កត្រ លុះទ្រង់ព្រះសណ្ដាប់ហើយទ្រង់ត្រាស់ថាចំពោះ

អស់កកម្មដ្ឋាននោះ ទ្រង់សព្វព្រះរាជហឫទ័យខ្លាំង ក៏បានប្រទានសមណស័ក្តិដល់លោក ទីជាព្រះគ្រូធម្មវិបស្សនាញាណ ។

កន្លងកាលដែលរាជការបារាំង-ខ្មែរ ចូលទៅរៀបចំខែត្របាត់ដំបង សៀមរាប បានដឹងរឿងរ៉ាវលោកគ្រូគុំសំពៅនោះសព្វគ្រប់ក៏មានសេចក្តីពេញចិត្តនឹងលោកគ្រូនោះថាជាមនុស្សបេះស្រឡាញ់ជាតិស្រឡាញ់ទឹកដីរបស់ខ្លួនមានចិត្តស្មោះត្រង់នឹងរាជការបារាំង-ខ្មែរ ក៏បានប្រគេនគ្រឿងឥស្សរិយយសដល់លោកជាច្រើន ។

លុះដល់មកថ្ងៃ ៦ ខែយ៉ាំងវិយេ ឆ្នាំ ១៩៣០ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់សព្វព្រះរាជហឫទ័យ បានប្រទានគ្រឿងឥស្សរិយយសមួយទៀតឈ្មោះ សេនាក្រុងកម្ពុជា (Officier de l'O. R. du Cambodge) ។

លោកគង់នៅក្នុងវត្តគុំសំពៅនោះ បង្ហាត់បង្រៀនកម្មដ្ឋានដល់ពួកបព្វជិតនិងគ្រហស្ថ កាន់តែចំរើនឡើងៗ មានឧបាសក - ឧបាសិកាចំណុះជើងវត្តច្រើនកុះករកើតបានជាឃុំ ១ ហៅថាឃុំគុំសំពៅ រហូតមកដល់សព្វថ្ងៃ ។

លុះដល់មកឆ្នាំ ១៩៣៧ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះរាជាក្រុងកម្ពុជា ទ្រង់សព្វព្រះរាជហឫទ័យទ្រង់តាំងព្រះគ្រូធម្មវិបស្សនាញាណ ឲ្យឡើងទីជាព្រះធម្មបរិយាយ ព្រឹទ្ធវិចិត្រសេដ្ឋាធិគណៈ មេគណខែត្របាត់ដំបង ។

ចាប់តាំងពីបានទៅជាមេគណឡើង លោកក៏ខំយកព្រះទ័យទុកដាក់ចាត់ចែងធ្វើកិច្ចការខាងគណសង្ឃ ឲ្យបានរៀបរយស្រួលបួលល្អក្នុងខែត្ររបស់លោក ។

លុះដល់មកក្នុងឆ្នាំរកាសប្តស័ក ព. ស. ២៤៨៨ ត្រូវនឹងឆ្នាំ ១៩៤៥ លោកក៏មានអាពាធជាទម្ងន់ ពួកញាតិមិត្រព្រមទាំងសិស្សានុសិស្សរបស់លោកបានខំរកពេទ្យមកប្រកបថ្នាំព្យាបាលរោគនោះ ក៏មិនបានធូរស្បើយសោះ មរណសង្គ្រាមចេះតែរុករានទន្ទ្រានចូលមកខ្លាំង លោកមិនអាចនឹងទប់ទល់បានក៏ទទួលអនិច្ចធម្មទៅក្នុងថ្ងៃ ១០ កើតខែភទ្របទ ឆ្នាំរកាសប្តស័ក ព. ស. ២៤៨៨ ត្រូវនឹងថ្ងៃ ១៦ ខែសេបតម្ប៍ ឆ្នាំ ១៩៤៥ ក្នុងជន្មាយុគំរប់ ៧១ ឆ្នាំ ។